ក- លោកស្រី **ហុក ភយ** ប្រធានគណៈកម្មការសហគមន៍នេសាទ ឫស្សីកែវ

- ដឹកនាំ និងទទួលខុសត្រូវរួមក្នុងការអនុវត្តការងារនៅក្នុងសហគមន៍នេសាទ
- សម្របសម្រួលការងារជាមួយស្ថាប័នជំនាញនិងអាជ្ញាធរមូលដ្ឋាន ដើម្បីគាំទ្រដល់ការងារសហគមន៍
- ទំនាក់ទំនងជាមួយ សមត្ថកិច្ចជលផល អាជ្ញាធរមូលដ្ឋាន និងអង្គការនានា ដើម្បីស្វែងរកជំនួយឧបត្ថម្ភ គាំទ្រផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ ទ្រទ្រង់សកម្មភាពសហគមន៍នេសាទ
- តាមដានត្រួតពិនិត្យរាល់សកម្មភាពការងាររបស់សហគមន៍នេសាទ
- សម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមានក្នុងសហគមន៍នេសាទ
- ដឹកនាំរាល់ការប្រជុំគណៈកម្មការសហគមន៍ និងមហាសន្និបាតសហគមន៍នេសាទក្នុងការបូកសរុបវាយតម្លៃ និងរៀបចំផែនការការងារ
- រៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការអណត្តិក្រោយតាមការកំណត់
- ទទួលខុសត្រូវរាល់ការចំណាយ ទៅតាមផែនការរបស់មហាសន្និបាតកំណត់
- ផ្តល់ភាពយុត្តិធម៌ និងតម្លាភាពដល់សមាជិកសហគមន៍
- ផ្ទេរភារកិច្ចជាលាយលក្ខណ៏អក្សរទៅអនុប្រធាន។

ខ- លោក **សុខ ធឿន** អនុប្រធានទី១គណៈកម្មការសហគមន៍នេសាទ
លោក **ភាក់ ចាន់** អនុប្រធានទី២គណៈកម្មការសហគមន៍នេសាទ

- ចូលរួមអនុវត្តការងារជាមួយប្រធាន

- ជួសមុខប្រធាននៅពេលប្រធានអវត្តមាន
- ទទួលភារកិច្ចផ្សេងៗ ដែលប្រធានប្រគល់ជូន ។

គ- លោកស្រី **ឡូញ ស្រីម៉ៅ** សមាជិកគណៈកម្មការសហគមន៍ទទួលបន្ទុកវារីវប្បកម្ម

- រៀបចំនិងប្រមូលឯកសារបច្ចេកទេសនានា ដែលទាក់ទងនឹងការងារវារីវប្បកម្ម
- ចូលរួមវគ្គបណ្តុះបណ្តាលនិងទស្សនៈកិច្ចសិក្សា ដើម្បីទទួលយកចំណេះដឹងបច្ចេកទេសវារីវប្បកម្មមកផ្សព្វផ្សាយក្នុងសហគមន៍នេសាទ
- រៀបចំគម្រោងនិងអនុវត្តន៍សកម្មភាពនៃគម្រោងវារីវប្បកម្មក្នុងសហគមន៍នេសាទ
- ធ្វើរបាយការណ៍ប្រចាំឆ្នាំនិងព្រាងរបាយការណ៍ពីលទ្ធផលការងារវារីវប្បកម្មរបស់សហគមន៍នេសាទដើម្បីដាក់ជូនប្រធានពិនិត្យនិងសម្រេច
- ទទួលភារកិច្ចផ្សេងៗដែលប្រធានប្រគល់ជូន ។

ឃ- លោក **សែម សុខា** សមាជិកគណៈកម្មការសហគមន៍ទទួលបន្ទុកអភិរក្សធនធានជលផល

- រៀបចំនិងប្រមូលឯកសារលិខិតបទដ្ឋានសម្រាប់ការបង្កើតកន្លែងអភិរក្សត្រីមេពូជនិងការគ្រប់គ្រងធនធានជលផល
- សិក្សានិងកំណត់កន្លែងអភិរក្សធនធានជលផលក្នុងសហគមន៍នេសាទ
- រៀបចំគម្រោងនិងអនុវត្តន៍សកម្មភាពនៃគម្រោងអភិរក្សធនធានជលផលក្នុងសហគមន៍នេសាទ
- ធ្វើរបាយការណ៍ប្រចាំឆ្នាំនិងព្រាងរបាយការណ៍ ពីលទ្ធផលការងារអភិរក្សរបស់សហគមន៍នេសាទដើម្បីដាក់ជូនប្រធានពិនិត្យនិងសម្រេច
- ទទួលភារកិច្ចផ្សេងៗដែលប្រធានប្រគល់ជូន។

ង- លោក **អឿ រស្មី** សមាជិកគណៈកម្មការសហគមន៍ទទួលបន្ទុកអប់រំ ផ្សព្វផ្សាយ

- អប់រំ ផ្សព្វផ្សាយ ច្បាប់ អនុក្រឹត្យ សេចក្តីជូនដំណឹង លិខិតបទដ្ឋាននានាដែលពាក់ព័ន្ធលើការគ្រប់គ្រងវិស័យជលផល បរិស្ថាន សិទ្ធិមនុស្ស សុខភាព និងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រងនិងកិច្ចព្រម ព្រៀងកន្លែងនេសាទសហគមន៍ ជូនដល់សមាជិកសហគមន៍របស់ខ្លួន និងសហគមន៍នេសាទជិតខាង
- រៀបចំឯកសារ ផ្លាកសញ្ញា និងរូបភាពផ្សេងៗសម្រាប់ធ្វើការអប់រំ ផ្សព្វផ្សាយ
- ស្វែងរកវិធីសាស្ត្រ និងបទពិសោធន៍ល្អៗ សម្រាប់ធ្វើការអប់រំ ផ្សព្វផ្សាយឱ្យរឹតតែមានប្រសិទ្ធភាព
- រៀបចំវគ្គបណ្តុះបណ្តាល ទស្សនៈកិច្ចសក្សា ដើម្បីលើកកំពស់កំរិតយល់ដឹង និងផ្លាស់ប្តូរបទពិសោធន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ
- តំណាងឱ្យសហគមន៍ក្នុងការសម្របសម្រួល និងដោះស្រាយទំនាស់ដែលកើតមាន
- ចូលរួមពិគ្រោះយោបល់ក្នុងការធ្វើបទបញ្ញានានាដែលពាក់ព័ន្ធផលប្រយោជន៍របស់សហគមន៍នេសាទ
- ធ្វើការតវ៉ាចំពោះការមិនបន្តកិច្ចព្រមព្រៀងឱ្យសហគមន៍នេសាទ
- ធ្វើរបាយការណ៍លទ្ធផលលើការងារអប់រំ និងការវាតំលៃផែនការអនុវត្ត ជូនប្រធានគណៈកម្មការសហគមន៏នេសាទជារៀងរាល់ខែ
- ទទួលភារកិច្ចផ្សេងៗដែលប្រធានប្រគល់ជូន។

- ចងក្រងឯកសារទាក់ទងនឹងផលចាប់ត្រី
- ទទួលភារកិច្ចផ្សេងៗដែលប្រធានប្រគល់ជូន។

ជ- លោកស្រី **យិន សុខគង់** សមាជិកគណៈកម្មការសហគមន៍ទទួលបន្ទុកអភិវឌ្ឍន៍សហគមន៍នេសាទ
- រៀបចំផែនការ តាមដាននិងវាយតម្លៃការអនុវត្តផែនការ
- ធ្វើសេចក្ដីសម្រេចលើការអភិវឌ្ឍសហគមន៍ ដោយមានការយល់ព្រមពីសមាជិកសហគមន៍នេសាទភាគច្រើន ស្របទៅតាមលក្ខន្តិកៈសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ដឹកនាំការអនុវត្តផែនការសកម្មភាពអភិវឌ្ឍក្នុងសហគមន៍នេសាទ
- ទទួលភារកិច្ចផ្សេងៗដែលប្រធានប្រគល់ជូន។

ឈ- លោក **ម៉ុក ឆាយ** សមាជិកគណៈកម្មការសហគមន៍ ទទួលបន្ទុកកិច្ចការរដ្ឋបាល និងលេខាកត់ត្រា
- ធ្វើកំណត់ហេតុ និងរបាយការណ៍រាល់សកម្មភាពរបស់សហគមន៍
- ពិនិត្យពាក្យស្នើសុំចូលជាសមាជិក និងសុំលាលែងពីសមាជិកសហគមន៍នេសាទ
- ធ្វើលិខិតអញ្ជើញសមាជិកសហគមន៍នេសាទឱ្យចូលរួមមហាសន្និបាតសាមញ្ញ
- រៀបចំបែបបទ និងលិខិតស្នាមផ្សេងៗដែលទាក់ទងការគ្រប់គ្រងសហគមន៍
- ទទួលពាក្យបណ្ដឹងតវ៉ាផ្សេងៗ ដែលទាក់ទងការគ្រប់គ្រងសហគមន៍
- រៀបចំបញ្ជីរាយនាមគណៈកម្មការ និងសមាជិកសហគមន៍នេសាទ
- កត់ត្រា និងគ្រប់គ្រងសម្ភាររបស់សហគមន៍នេសាទ
- ធ្វើរបាយការណ៍ប្រចាំឆ្នាំ និងព្រាងរបាយការណ៍ ពីលទ្ធផលការងាររបស់សហគមន៍នេសាទ ដើម្បីដាក់ជូនប្រធានពិនិត្យនិងសម្រេច
- ចងក្រង និងរក្សាទុកឯកសារផ្សេងៗ
- ទទួលភារកិច្ចផ្សេងៗដែលប្រធានប្រគល់ជូន។

ញ- លោក **អ៊ុយ សារុន** សមាជិកគណៈកម្មការសហគមន៍ ទទួលបន្ទុកគណនេយ្យ
- ទទួលខុសត្រូវហិរញ្ញវត្ថុរបស់សហគមន៍នេសាទទាំងមូល
- គ្រប់គ្រង និងចុះបញ្ជីគណនេយ្យរបស់សហគមន៍នេសាទឱ្យបានត្រឹមត្រូវតាមប្រព័ន្ធការងារគណនេយ្យ
- រៀបចំគំរោងផែនការប្រើប្រាស់ហិរញ្ញវត្ថុរបស់សហគមន៍ដើម្បីគណៈកម្មការសហគមន៍នេសាទពិនិត្យនិងសម្រេច និងស្នើសុំការឯកភាពពីសមាជិកគណៈកម្មាការសហគមន៍នេសាទ នូវរាល់ចំណាយផ្សេងៗ
- ធ្វើបញ្ជីចំណូល ចំណាយ របស់សហគមន៍នេសាទឱ្យបានត្រឹមត្រូវ
- រៀបចំរបាយការណ៍ពីស្ថានភាពចំណូល ចំណាយជូនប្រធានគណៈកម្មការជារៀងរាល់ខែ
- រក្សាទុករាល់ឯកសារចំណូល ចំណាយរបស់សហគមន៍នេសាទ
- រៀបចំបែបបទ និងទទួលប្រាក់សមាជិកភាព និងភាគទានប្រចាំឆ្នាំពីសមាជិក
- រាល់ការចំណាយត្រូវមានការឯកភាពពីប្រធានឬគណៈកម្មការសហគមន៍នេសាទ
- រាល់ការចំណាយ ត្រូវមានរបាយការណ៍ទូទាត់ដោយមានសក្ខីប័ននិងចុះបញ្ជីឱ្យបានត្រឹមត្រូវ
- ថវិកាដែលត្រូវចំណាយ គឺសម្រាប់តែបម្រើឱ្យការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍសហគមន៍នេសាទ
- ទទួលភារកិច្ចផ្សេងៗដែលប្រធានប្រគល់ជូន។

**ប្រការ១-**

បុគ្គលដែលត្រូវជាឪពុកម្តាយបងប្អូនបង្កើតបងប្អូនជីដូនមួយ ប្តី ប្រពន្ធជាមួយនឹងប្រធានគណៈកម្មការសហគមន៍ ពុំអាចចាត់តាំងឱ្យធ្វើជាសមាជិកគណៈកម្មការ ទទួលបន្ទុកគណនេយ្យឬបេឡាបានទេ។

**ប្រការ២-**

គណៈកម្មការសហគមន៍នេសាទ ស្ម័គ្រចិត្តបំពេញការងារ សហគមន៍នេសាទដោយពុំទទួលប្រាក់ខែពីសហគមន៍នេសាទ ។

**ប្រការ៣-**

គណៈកម្មការសហគមន៍នេសាទត្រូវធ្វើការប្រជុំយ៉ាងតិចក្នុងមួយខែម្តង (១ខែម្តង) ក្នុងករណីចាំបាច់គណៈកម្មការ សហគមន៍នេសាទអាចធ្វើការប្រជុំពិសេស ។

**ប្រការ៤-**

ប្រធានគណៈកម្មការសហគមន៍នេសាទជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំសហគមន៍នេសាទរបស់ខ្លួន ។

ក្នុងករណីប្រធានគណៈកម្មការសហគមន៍នេសាទ អវត្តមានសមាជិកគណៈកម្មការសហគមន៍នេសាទដែលមានឋានានុក្រមបន្ទាប់ ត្រូវធ្វើជាប្រធានអង្គប្រជុំជំនួស ។

ប្រធានអង្គប្រជុំ ត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យ និងមាន របៀបរៀបរយ ។

ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិកនោះចចេស រឹងរូសធ្វើឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ ។

សេចក្តីសម្រេចនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈសហគមន៍នេសាទ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ឫស្សីកែវ |
| ភូមិ | ៖ | ឫស្សីកែវ ស្វាយជុំ បឹងរ៉ៃ និងស្រឡៅដំណាក់ |
| ឃុំ | ៖ | ឫស្សីកែវ |
| ស្រុក | ៖ | ព្រែកប្រសព្វ |
| ខេត្ត | ៖ | ក្រចេះ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈសហគមន៍នេសាទ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ឬស្សីកែវ |
| ភូមិ | ៖ | ឬស្សីកែវ ស្វាយជុំ បឹងរៃ និងស្រឡៅដំណាក់ |
| ឃុំ | ៖ | ឬស្សីកែវ |
| ស្រុក | ៖ | ព្រែកប្រសព្វ |
| ខេត្ត | ៖ | ក្រចេះ |

# ជំពូកទី ១
# គោលបំណង និងនាមករណ៍

**ប្រការ ១.-**

លក្ខន្តិកៈនេះមានគោលបំណង៖

- កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍ ការប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព
- ធ្វើជាគោលការណ៍គ្រឹះ និងជាយន្តការសម្រាប់ដំណើរការសហគមន៍នេសាទ
- ការពារសិទ្ធិនិងផលប្រយោជន៍របស់សមាជិកសហគមន៍នេសាទ និងផលប្រយោជន៍សាធារណៈ។

**ប្រការ ២.-**

ឈ្មោះសហគមន៍នេសាទឫស្សីកែវ ហៅកាត់ថា ស.ន.ឫ.ក ដែលមានអាស័យដ្ឋាននៅភូមិឫស្សីកែវ ឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។

សហគមន៍នេសាទនេះ មានការចូលរួមពីប្រជាពលរដ្ឋដែលរស់នៅក្នុង៖

| | | | |
|---|---|---|---|
| ១- ភូមិឫស្សីកែវ | ឃុំឫស្សីកែវ | ស្រុកព្រែកប្រសព្វ | ខេត្តក្រចេះ |
| ២- ភូមិស្រឡៅដំណាក់ | ឃុំឫស្សីកែវ | ស្រុកព្រែកប្រសព្វ | ខេត្តក្រចេះ |
| ៣- ភូមិបឹងរ៉ៃ | ឃុំឫស្សីកែវ | ស្រុកព្រែកប្រសព្វ | ខេត្តក្រចេះ |
| ៤- ភូមិស្វាយជុំ | ឃុំឫស្សីកែវ | ស្រុកព្រែកប្រសព្វ | ខេត្តក្រចេះ |

**មានកម្មវត្ថុ៖** ដើម្បីថែរក្សា ការពារ ប្រើប្រាស់ អភិរក្ស អភិវឌ្ឍ និងគ្រប់គ្រងធនធានជលផលឱ្យបានយូរអង្វែង។

# ជំពូកទី ២
# លក្ខខណ្ឌនៃការសុំចូលជាសមាជិក ភារកិច្ចនិងសិទ្ធិរបស់សមាជិក

**ប្រការ ៣.-**

ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងចង់ចូលជាសមាជិកសហគមន៍នេសាទមានសិទ្ធិដាក់ពាក្យចូលដោយស្ម័គ្រចិត្តនិងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- មានលំនៅដ្ឋាននៅក្នុងបណ្តាភូមិនៃសហគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី១៨ឆ្នាំឡើង។

**ប្រការ ៤.-**

សមាជិកសហគមន៍នេសាទដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ៣ ខាងលើមានសិទ្ធិ៖

- ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា
- បោះឆ្នោត និងឈរឈ្មោះជាបេក្ខជននៃគណៈកម្មការសហគមន៍នេសាទស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ
- ទទួលព័ត៌មានពីស្ថានភាពសេដ្ឋកិច្ច សង្គមរបស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើ

មានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី(១/៣)នៃសមាជិកសហគមន៍នេសាទទាំងអស់

- ធ្វើនេសាទជាលក្ខណៈគ្រួសារស្របតាមច្បាប់ស្តីពីជលផល កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធវិស័យជលផល
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ
- ប្តឹងតវ៉ាឬផ្តល់ព័ត៌មានពីបាតុភាពទាំងឡាយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ ទៅសមត្ថកិច្ចរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ
- ទទួលការគាំទ្រពីមជ្ឈដ្ឋាននានាដើម្បីផលប្រយោជន៍របស់សហគមន៍។

សមាជិកសហគមន៍នេសាទត្រូវទទួលខុសត្រូវរាល់សកម្មភាពរៀងៗខ្លួន និងរួមគ្នាចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ។

សមាជិកសហគមន៍នេសាទចំនួនមួយភាគដប់(១/១០)ឡើងទៅ អាចស្នើសុំឱ្យប្រធានគណៈកម្មការសហគមន៍នេសាទបញ្ចូលបញ្ហាមួយចំនួនទៅក្នុងរបៀបវារៈ នៃកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទសាមី ហើយចំនួនសមាជិកសហគមន៍នេសាទ ដែលបានស្នើសុំខាងលើនេះអាចចាត់តំណាងចំនួនបី(៣) នាក់ចូលរួមប្រជុំដើម្បីចោទសួរគណៈកម្មការសហគមន៍នេសាទនូវបញ្ហាទាំងឡាយណា ដែលទាក់ទង នឹងចំណុចដែលបានស្នើឡើងនោះ។

**ប្រការ ៥.-**

សមាជិកសហគមន៍នេសាទមានកាតព្វកិច្ចនិងភារកិច្ចដូចខាងក្រោម៖

- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជលផល
- អនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- អនុវត្តតាមអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងលិខិតបទដ្ឋានផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ
- អនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាតនិងគណៈកម្មការសហគមន៍នេសាទ
- បង់ប្រាក់សមាជិកភាពចំនួន៥ ០០០រៀល (ប្រាំពាន់រៀល) តាមការសម្រេចរបស់មហាសន្និបាតនៅពេលដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- បង់ប្រាក់ភាគទានប្រចាំឆ្នាំចំនួន២ ០០០រៀល(ពីរពាន់រៀល) តាមការសម្រេចរបស់មហាសន្និបាត
- ចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទ ដើម្បីផលប្រយោជន៍និងការរីកចំរើនរបស់សហគមន៍នេសាទ
- ចូលរួមការពារ ថែរក្សា និងគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ
- ចូលរួមឃ្លាំមើលទប់ស្កាត់ និងរាយការណ៍រាល់សកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍។

## ជំពូកទី ៣
## លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញពីសមាជិក

**ប្រការ ៦.-**

សមាជិកសហគមន៍នេសាទមានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ៖

- ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្សរ
- ការផ្លាស់ប្តូរទីលំនៅចេញពីកន្លែងនេសាទសហគមន៍

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច។

**ប្រការ ៧.-**

សមាជិកសហគមន៍អាចត្រូវបណ្តេញចេញពីសមាជិកភាពក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- ការមិនបង់ភាគទានចំនួន៣ លើកជាប់ៗគ្នា
- ការធ្វើឱ្យប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍នៃសហគមន៍នេសាទ ឬសមាជិកសហគមន៍នេសាទដទៃទៀត
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម
- សាមីខ្លួនបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ។

## ជំពូកទី ៤
## របៀបរបបកាន់បញ្ជី និង ឯកសារនានា

**ប្រការ ៨.-**

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី៖

- ភាគទានសមាជិកភាព និងភាគទានប្រចាំឆ្នាំរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល
- ចំណូលស្របច្បាប់ផ្សេងៗទៀត។

**ប្រការ ៩.-**

រាល់ការចំណាយថវិកាសហគមន៍ត្រូវអនុវត្តដូចតទៅ៖

- ការចំណាយពី១០០រៀល (មួយរយរៀល) ដល់ ៥០ ០០០រៀល (ប្រាំម៉ឺនរៀល) ត្រូវសម្រេចដោយប្រធានគណៈកម្មការសហគមន៍នេសាទ
- ការចំណាយពី៥០ ១០០រៀល (ប្រាំម៉ឺនមួយរយរៀល) ដល់១០០ ០០០រៀល (ដប់ម៉ឺនរៀល) ត្រូវសម្រេចដោយគណៈកម្មការសហគមន៍នេសាទ
- ការចំណាយពី១០០ ១០០រៀល (ដប់ម៉ឺនមួយរយរៀល) ឡើងទៅត្រូវសម្រេចដោយមហាសន្និបាត។

**ប្រការ ១០.-**

សហគមន៍នេសាទត្រូវតម្កល់ទុកឯកសារ និងរៀបចំឱ្យមានបញ្ជី៖

- ចំណូល ចំណាយថវិកា
- សារពើភ័ណ្ឌ
- សមាជិកសហគមន៍នេសាទ
- កំណត់ហេតុប្រជុំមហាសន្និបាតសហគមន៍នេសាទ
- កំណត់ហេតុប្រជុំគណៈកម្មការសហគមន៍នេសាទ
- ឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

**ប្រការ ១១.-**

ការគ្រប់គ្រង និងប្រើប្រាស់ថវិកាៈ

- ការគ្រប់គ្រងថវិកាត្រូវមានការកាន់បញ្ជីគណនេយ្យ
- ថវិកាចំណូល ដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកក្នុងបេឡារបស់សហគមន៍នេសាទ
- រាល់ថវិកាចំណាយ ត្រូវមានរបាយការណ៍ទូទាត់ដោយមានសក្ខីបត្រនិងចុះបញ្ជីឱ្យបានត្រឹមត្រូវ
- ថវិកាដែលត្រូវចំណាយ គឺសម្រាប់តែបម្រើឱ្យការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍសហគមន៍នេសាទ។

## ជំពូកទី ៥
## គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១២.-**

សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន ប្រធាន អនុប្រធាន និងសមាជិក។ គណៈកម្មការសហគមន៍នេសាទត្រូវបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការមួយរូប និងសមាជិកទទួលបន្ទុកហិរញ្ញិកមួយរូប និងត្រូវពិភាក្សាបែងចែកភារកិច្ចសមាជិកផ្សេងទៀតតាមការជាក់ស្តែង។

ប្រធានគណៈកម្មការសហគមន៍នេសាទទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទទាំងមូល។ អនុប្រធានគណៈកម្មការសហគមន៍នេសាទជាជំនួយការឱ្យប្រធាន ។

**ប្រការ ១៣.-**

គណៈកម្មការសហគមន៍នេសាទមានអាណត្តិប្រាំ(៥)ឆ្នាំចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មី ដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុង មហាសន្និបាតឱ្យចូលកាន់តំណែងជំនួស។ ក្នុងករណីសហគមន៍នេសាទដំណើរការមិនប្រក្រតីដោយ មូលហេតុដំណើរការមិនល្អ ឬអសមត្ថភាពក្នុងការគ្រប់គ្រងសហគមន៍នេសាទសមាជិកសហគមន៍នេសាទចំនួនមួយភាគបី(១/៣) មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មី។

**ប្រការ ១៤.-**

ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍នេសាទណាម្នាក់អវត្តមានដោយគ្មានមូលហេតុរយៈពេលបី(៣)ខែ ឬសុំលាលែងមុនចប់អាណត្តិបេក្ខជន ដែលមានឈ្មោះតាមសម្លេងគាំទ្របន្ទាប់ក្នុងពេលបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតកន្លងមកត្រូវបានជ្រើសតាំងជំនួស ។

## ជំពូកទី ៦
## របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១៥.-**

គណៈកម្មការសហគមន៍នេសាទត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់រៀងរាល់ខែ។ កិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចចំនួន២/៣ (ពីរភាគបី) នៃសមាជិករបស់គណៈកម្មការសហគមន៍នេសាទទាំងមូល។

**ប្រការ ១៦.-**

ប្រធានគណៈកម្មការសហគមន៍នេសាទជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំ។ ក្នុងករណីប្រធានគណៈកម្មការសហគមន៍នេសាទអវត្តមាន អនុប្រធានដែលបានការប្រគល់សិទ្ធិត្រូវធ្វើជាប្រធានអង្គប្រជុំ។ រាល់ការប្រជុំត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់។

ប្រធានអង្គប្រជុំត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅដោយលក្ខណៈ ប្រជាធិបតេយ្យមានរបៀបរៀបរយ និងគ្មានការរំខាន។

ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបានក្នុងករណីដែលសមាជិកនោះធ្វើឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ។

**ប្រការ ១៧.-**

ការសម្រេចលើបញ្ហាណាមួយរបស់សហគមន៍ដូចមានចែងខាងក្រោមនេះគឺ ត្រូវអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ដោយមានសម្លេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទដែលមានវត្តមានក្នុងអង្គប្រជុំ។ ក្នុងករណីដែលមានសម្លេងស្មើគ្នា មតិប្រធានអង្គប្រជុំជាឧត្តមានុភាព៖

- សេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងសហគមន៍នេសាទ
- ការព្យួរសមាជិកភាពរបស់សមាជិកដែលមានកំហុស
- ការទទួលពាក្យសុំចូលជាសមាជិកថ្មី
- ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុង ដល់សមាជិកសហគមន៍នេសាទ។

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម ប្រធានគណៈកម្មការសហគមន៍នេសាទត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមាជិកសហគមន៍នេសាទពីសេចក្តីសម្រេចរបស់ខ្លួន។ សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហគមន៍នេសាទត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការសហគមន៍នេសាទឬសាលាឃុំ ក្នុងរយៈពេល៧ថ្ងៃយ៉ាងយូរបន្ទាប់ពីការប្រជុំ។

## ជំពូកទី ៧
## មហាសន្និបាតសហគមន៍នេសាទ

**ប្រការ ១៨.-**

មហាសន្និបាតសហគមន៍នេសាទជាអង្គប្រជុំកំពូលដើម្បីធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចចិត្តទាំងឡាយក្នុងនាមសហគមន៍នេសាទ។ មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទត្រូវប្រារព្ធធ្វើឡើងបន្ទាប់ពីក្រុម-ស្ថាបនិកបានរៀបចំរួចរាល់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹង ដំណើរការមហាសន្និបាត។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទធ្វើឡើងដោយក្រុមប្រឹក្សាឃុំ ដោយមានការជួយសម្របសម្រួលពីសមត្ថកិច្ចរដ្ឋបាលជលផលតាមការស្នើសុំរបស់ក្រុមស្ថាបនិកហើយត្រូវមានការចូលរួមពីសមាជិកដែលបានដាក់ពាក្យស្នើសុំរួចមកហើយ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទអនុម័តនូវសេចក្តីសម្រេចនិងកិច្ចការសំខាន់ដូចខាងក្រោម៖

- អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- ឈ្មោះសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ។

**ប្រការ ១៩.-**

មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង១ឆ្នាំម្តង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំ និងអនុម័តនូវកិច្ចការសំខាន់ៗ របស់សហគមន៍នេសាទ។ ក្នុងករណីចាំបាច់សហគមន៍អាចរៀបចំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំពីសមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣)យ៉ាងតិច។

**ប្រការ ២០.-**

គណៈកម្មការសហគមន៍នេសាទអាចអញ្ជើញរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សមត្ថកិច្ចពាក់ព័ន្ធ និងអ្នកគាំទ្រចូលរួមសង្កេតការណ៍ឬសម្របសម្រួល ឬជាកិត្តិយសក្នុងមហាសន្និបាតសហគមន៍នេសាទ។

**ប្រការ ២១.-**

លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម៖

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងជាសាធារណៈ និងបិទប្រកាសនៅសាលាឃុំ និងទីស្នាក់ការសហគមន៍នេសាទ
- ការកោះអញ្ជើញសមាជិកសហគមន៍នេសាទឱ្យចូលរួមមហាសន្និបាតសាមញ្ញត្រូវធ្វើឡើងដប់(១០)ថ្ងៃយ៉ាងតិចមុនថ្ងៃបើកមហាសន្និបាត និងបី(៣)ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ
- មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញអាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបានលុះត្រាតែមានវត្តមានលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទ
- អង្គប្រជុំមហាសន្និបាតដឹកនាំដោយប្រធានគណៈកម្មការសហគមន៍នេសាទ ឬប្រធានអង្គប្រជុំដែលជ្រើសរើសដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន
- មហាសន្និបាតត្រូវអនុម័តលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុសេចក្តីសម្រេច និងបញ្ជីវត្តមាន
- លេខាកត់ត្រា និងប្រធានអង្គប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុ
- សមាជិកម្នាក់មានសម្លេងតែមួយគត់ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
- សេចក្តីសម្រេចរបស់មហាសន្និបាតត្រូវយកសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកដែលមានវត្តមាន។

**ប្រការ ២២.-**

មហាសន្និបាតអនុម័ត៖

- សេចក្តីសម្រេចដូចមានចែងក្នុងប្រការ១៨ កថាខណ្ឌទី ៣ លក្ខន្តិកៈនេះ
- កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- ការសុំលាលែង ឬការបណ្តេញចេញពីសមាជិកភាព ឬពីសមាជិកគណៈកម្មការសហគមន៍នេសាទ
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ
- គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ

## ជំពូកទី ៨
## ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

**ប្រការ ២៣.-**

ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទនិងចំនួនបេក្ខជនឈរឈ្មោះត្រូវអនុម័តដោយមហាសន្និបាត។

**ប្រការ ២៤.-**

កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ គឺជាភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោត ដែលអនុម័តដោយមហាសន្និបាត។ គណៈកម្មការរៀបចំការបោះឆ្នោតមានសមាសភាពពីបី(៣) ទៅប្រាំ(៥)នាក់ដែលមានប្រធានអនុប្រធាន និងសមាជិកតាមការកំណត់ជាក់ស្តែងរបស់មហាសន្និបាត និងត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានចំណេះដឹង និងមានសីលធម៌ល្អ។ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវធ្វើការប្តេជ្ញាចិត្តបង្ហាញពីភាពស្មោះត្រង់។

**ប្រការ ២៥.-**

គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ច ដូចខាងក្រោម៖

- ប្រកាសបេក្ខជនឈរឈ្មោះ
- ណែនាំអំពីនីតិវិធីនៃការបោះឆ្នោត
- បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតីដើម្បីប្រកាសជូនមហាសន្និបាត
- ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតចប់ជាស្ថាពរ។

**ប្រការ ២៦.-**

បេក្ខជនដែលទទួលបានសម្លេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ។ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ត្រូវទទួលតួនាទីជាអនុប្រធានជាសមាជិកគណៈកម្មការសហគមន៍នេសាទតាមលំដាប់លំដោយ។ ក្នុងករណីបេក្ខជន ដែលមានសំឡេងគាំទ្រស្មើគ្នាត្រូវជ្រើសរើសស្ត្រី ឬបោះឆ្នោតរកអ្នកដែលមានសមត្ថភាពដោយលើកដៃយកមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទដែលចូលរួម ឬបេក្ខជនដែលមានសម្លេងស្មើគ្នាធ្វើការចាប់ឆ្នោតដើម្បីជ្រើសរើសយកម្នាក់។

## ជំពូកទី ៩
## លក្ខខណ្ឌនៃការរំលាយសហគមន៍នេសាទនិងនីតិវិធីដោះស្រាយវិវាទ

**ប្រការ ២៧ .-**

ការរំលាយសហគមន៍នេសាទត្រូវផ្អែកតាម៖

- សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថាមានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- សេចក្តីសម្រេចមហាសន្និបាតក្រោយពីរំលាយសហគមន៍នេសាទទ្រព្យសម្បត្តិរបស់សហគមន៍ត្រូវចាត់ចែងតាមការអនុម័តរបស់មហាសន្និបាតលើកលែងតែដែននេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ។

**ប្រការ ២៨.-**

ក្នុងករណីមានការតវ៉ាចោទប្រកាន់ថា ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទមានភាពមិនប្រក្រតីអ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់ពីភាពមិនប្រក្រតីនោះភ្លាមនៅមុនពេលប្រកាសលទ្ធផលបោះឆ្នោតដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យនិងសម្រេច។

**ប្រការ ២៩.-**

វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម៖

- គណៈកម្មការសហគមន៍នេសាទត្រូវសម្រុះសម្រួល និងដោះស្រាយរាល់វិវាទ ដែលកើតមានឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន
- ក្នុងករណីគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផល ដើម្បីដោះស្រាយទៅតាមឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់
- ក្នុងករណីបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និងរដ្ឋបាលជលផលត្រូវបញ្ជូនសំណុំរឿងទៅតុលាការខេត្ត ក្រុងសាមី ដើម្បីដោះស្រាយតាមផ្លូវច្បាប់។

**ប្រការ ៣០.-**

សមាជិកសហគមន៍នេសាទរូបណា ដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវទទួលទណ្ឌកម្មពីគណៈកម្មការសហគមន៍នេសាទ ឬមហាសន្និបាតសហគមន៍នេសាទទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន។

## ជំពូកទី ១០
## នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

**ប្រការ ៣១.-**

ការកែប្រែលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវសម្រេចដោយមហាសន្និបាត។ ការលើកសំណើកែប្រែលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ត្រូវធ្វើឡើងដោយសមាជិកយ៉ាងតិចមួយភាគបី(១/៣)នៃសមាជិកសហគមន៍នេសាទទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការសហគមន៍នេសាទមួយខែមុនបើកមហាសន្និបាត។ លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងនេះអាចកែប្រែបានលុះត្រាតែមានសំឡេងយល់ព្រមលើសពីពាក់កណ្តាល នៃសមាជិកមហាសន្និបាតសហគមន៍នេសាទ។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**ប្រការ ៣២.**

លក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវបានរៀបចំ និងអនុម័ត ដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូងនៅថ្ងៃទី...២៤... ខែ...កក្កដា... ឆ្នាំ២០១៩... និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។

ថ្ងៃ...ព្រហស្បតិ៍...៩...កើត...ខែ...អាសាឍ...ឆ្នាំ...កុរ......ឯកស័ក ព.ស២៥៦៣

ឬស្សីកែវ.ថ្ងៃទី......២៤......ខែ......កក្កដា......ឆ្នាំ២០១៩.....

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ហុក គយ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ឫស្សីកែវ |
| ភូមិ | ៖ | ឫស្សីកែវ ស្វាយជុំ បឹងរៃ និងស្រឡៅដំណាក់ |
| ឃុំ | ៖ | ឫស្សីកែវ |
| ស្រុក | ៖ | ព្រែកប្រសព្វ |
| ខេត្ត | ៖ | ក្រចេះ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ឫស្សីកែវ |
| ភូមិ | ៖ | ឫស្សីកែវ ស្វាយជុំ បឹងរ៉ៃ និងស្រឡៅជំណាក់ |
| ឃុំ | ៖ | ឫស្សីកែវ |
| ស្រុក | ៖ | ព្រែកប្រសព្វ |
| ខេត្ត | ៖ | ក្រចេះ |

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ដើម្បីធានាការគ្រប់គ្រងសហគមន៍នេសាទឱ្យប្រព្រឹត្តទៅមានប្រសិទ្ធភាព និងមានរបៀបរៀបរយល្អ សហគមន៍នេសាទឬស្សីកែវ សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម ៖

**ប្រការ ១.-**

គណៈកម្មការ និងសមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវមានការស្មោះត្រង់សាមគ្គីភាព ឯកភាពផ្ទៃក្នុង ជួយស្ថាបនា ព្រមទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចម្រើនរបស់សហគមន៍នេសាទ។

**ប្រការ ២.-**

គណៈកម្មការសមាជិកសហគមន៍នេសាទ ឬបុគ្គលណាដែលបានកេងប្រវ័ញ្ច ធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ និងផលប្រយោជន៍សហគមន៍នេសាទត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ ៖

- ចំពោះសមាជិកសហគមន៍នេសាទ ឬបុគ្គលដទៃទៀតត្រូវសងឬ ទូទាត់ទៅតាមទំហំនៃការខូចខាត ជាក់ស្តែងតាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍នេសាទ។ ក្នុងករណីមិនព្រមសងត្រូវដាក់ជូនមហាសន្និបាតសម្រេច
- ចំពោះគណៈកម្មការសហគមន៍នេសាទត្រូវសង ឬទូទាត់សងការខូចខាតតាមការសម្រេចរបស់មហាសន្និបាត ប្រសិនបើនីតិវិធីខាងលើនេះ នៅតែមិនអាចដោះស្រាយបាន គឺត្រូវអនុវត្តតាមផ្លូវច្បាប់ និងបទបញ្ជាជាធរមាន។

**ប្រការ ៣.-**

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវតែចូលរួមមហាសន្និបាត និងរាល់កិច្ចប្រជុំរបស់សហគមន៍នេសាទតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។ ក្នុងករណីដែលសមាជិកសហគមន៍ណាមិនបានមកចូលរួម ប្រជុំចំនួន៣ដងជាប់គ្នា ដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍នេសាទ។ ករណីនៅតែមិនរាងចាលគណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់ពីសមាជិកភាព។

**ប្រការ ៤ .-**

សិទ្ធិដាក់ទណ្ឌកម្ម ៖

**ក- គណៈកម្មការសហគមន៍នេសាទ**

- អប់រំណែនាំលើកទី១ លើកទី២ លើកទី៣
- ព្រមានផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ
- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ
- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច
- ផ្អាកការនេសាទ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅសមត្ថកិច្ចរដ្ឋបាលជលផល ចំពោះការនេសាទលើសទំហំ ចំនួន និងខុសប្រភេទ ពេលវេលា ទីតាំង តាមការកំណត់នៅក្នុងផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងនៅក្នុងកន្លែងនេសាទសហគមន៍។

**ខ- មហាសន្និបាត**

- អនុម័តការបណ្តេញចេញដូចមានចែងក្នុងប្រការ៧ នៃលក្ខន្តិកៈសហគមន៍នេសាទ
- សម្រេចលើសំណងការខូចខាតលើទ្រព្យសម្បត្តិសហគមន៍នេសាទ
- ដាក់ទណ្ឌកម្មដល់គណៈកម្មការនិងសមាជិកឬបុគ្គលដទៃ ដែលគណៈកម្មការមិនអាចដោះស្រាយបាន។

**ប្រការ ៥ .-**

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទពីសម្ភារៈ ឧបករណ៍នេសាទដែលគ្រួសារនីមួយៗ ប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍។

**ប្រការ ៦ .-**

សមាជិកសហគមន៍នេសាទអាចប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ ដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងកន្លែងនេសាទសហគមន៍នៅក្នុងរដូវបើកនិងបិទនេសាទ ផ្អែកតាមប្រកាសលេខ ៤៥៨ ប្រក.កសក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាតឲ្យប្រើធ្វើនេសាទក្នុងដែននេសាទទឹកសាបនៃព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

សមាជិកសហគមន៍នេសាទអាចប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងកន្លែងនេសាទសហគមន៍នៅក្នុងរដូវបើកនេសាទដូចខាងក្រោម៖

- **មងប្រវែង៖ ៤០០ម៉ែត្រ/គ្រួសារ (រដូវបិទនេសាទ១០០ម៉ែត្រ)**
- **សន្ទូច ៖ ៤០០ផ្លែ/គ្រួសារ**
- **សំណាញ់ ៖ ៥០វង់**
- **លប (០,៣មx១ម)៖ ២០គ្រឿង/គ្រួសារ**
- **តុម ១២០គ្រឿង**

ហាមឃាត់ដាច់ខាតចំពោះការធ្វើនេសាទគ្រប់ប្រភេទនៅក្នុងដែននេសាទឬកន្លែងនេសាទសហគមន៍ដោយប្រើប្រាស់ឧបករណ៍ដូចខាងក្រោម៖

- ឧបករណ៍ឆក់គ្រឿងផ្ទុះ និងសារធាតុពុលគ្រប់ប្រភេទ
- ឧបករណ៍បូមបាចពង្រីងផ្ទៃកណាមួយនៃដែននេសាទ ដែលបង្កមហន្តរាយដល់ធនធានជលផល
- សម្រាស់ឬមធ្យោបាយផ្សេងទៀតដែលធ្វើឱ្យត្រី ឬវារីសត្វគុំ
- ច្បូកសាងស្ទ ឬឧបករណ៍បាញ់ព្រួញដែលរួមផ្សំគ្រឿងផ្ទុះ
- មងបោះ មងកាំង ឬមងពស់ថ្លាន់គ្រប់ប្រភេទ
- មង ឬអួនគ្រប់ប្រភេទដែលមានក្រឡាតូចជាងមួយសង្ទីម៉ែត្រកន្លះ(១,៥ស.ម)ក្នុងដែននេសាទទឹកសាប ឬកន្លែងនេសាទសហគមន៍
- មងគ្រប់ប្រភេទដែលមានក្រឡាធំជាងដប់ប្រាំ(១៥) សង្ទីម៉ែត្រក្នុងដែននេសាទទឹកសាបឬកន្លែងនេសាទសហគមន៍
- អួនអូសគូ ឬអួនហ៊ុមរួមផ្សំភ្លើងដែលធ្វើឱ្យត្រីឬវារីសត្វគុំ
- ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទនៅទឹកសាប
- អួនអូសគ្រប់ប្រភេទនៅទឹកសាប និងឈិបយន្ត
- ព្រួលគ្រប់ប្រភេទដែលមានចន្លោះពីត្រៀមមួយទៅត្រៀមមួយតូចជាងមួយសង្ទីម៉ែត្រកន្លះ(១,៥ស.ម)។
- ខ្សែចងគ្រប់ប្រភេទនិងមធ្យោបាយផ្សេងៗទៀតដែលបង្កលក្ខណៈឱ្យត្រីផ្អើល
- ទំនប់រួមផ្សំដោយឧបករណ៍នេសាទគ្រប់ប្រភេទ
- ឧបករណ៍នេសាទទំនើប ឬឧបករណ៍ដែលបង្កើតថ្មី ឬរបៀបនេសាទបែបថ្មី ដែលនាំមកនូវការបំផ្លាញមច្ឆជាតិធនធានជលផលប្រព័ន្ធអេកូឡូស៊ីជលផល ឬដែលគ្មានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ហាមឃាត់ការផលិត ការទិញ ការលក់ ការដឹកជញ្ជូន ការរក្សាទុកឧបករណ៍ឆក់ ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ អួនអូសគូ ឈិបយន្ត និងអួនអូសទឹកសាបក្នុងបំណងធ្វើនេសាទ។

- ហាមឃាត់ការចាក់ចោលការបោះចោលការបង្ហូរ ឬការបាចពង្រាយទៅក្នុងដែននេសាទនូវកាកសំណល់រឹង ឬរាវ សារធាតុពុលដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញា ឬសន្ធិសញ្ញាអន្តរជាតិស្តីពីការបំពុលបរិស្ថាន ឬការប្រព្រឹត្តសកម្មភាពដែលធ្វើឱ្យពុល ឬការបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិ
- ហាមឃាត់ដាច់ខាតការធ្វើនេសាទគ្រប់ប្រភេទគ្រប់ប្រភេទនៅអន្លង់អភិរក្សឬកន្លែងអភិរក្សត្រីមេពូជ
- ហាមឃាត់ដាច់ខាតការជីករណ្តៅធំៗ ឬ បៀ ឬ រួមផ្សំដោយសម្រាស់។

**ប្រការ ៧.-**

សមាជិកសហគមន៍នេសាទដែល ៖

- ប្រព្រឹត្តផ្ទុយ ឬរាំងមិនឱ្យសមាជិកដទៃអនុវត្តសិទ្ធិ និងកាតព្វកិច្ចដូចក្នុងប្រការ៥នៃលក្ខន្តិកៈ ត្រូវព្យួរសមាជិកភាព ដោយគណៈកម្មការសហគមន៍នេសាទ ឬបណ្តេញចេញពីសមាជិកភាពដោយមហាសន្និបាត
- មិនចូលរួមថែរក្សាការពារធនធានជលផល ឬមិនរាយការណ៍អំពីសកម្មភាពបទល្មើសជលផលត្រូវព្រមានដោយគណៈកម្មការសហគមន៍នេសាទ
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ កាប់ឆ្ការរានព្រៃលិចទឹកត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពីជលផល
- ធ្វើនេសាទក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ ហើយរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលជលផលមានសមត្ថកិច្ច
- អនុវត្តផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ឬផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវផ្អាកការនេសាទទទួលការព្រមានជាលាយលក្ខណ៍អក្សរ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ជូនទៅរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីដោះស្រាយតាមច្បាប់ ។

**ប្រការ ៨.-**

ចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ ឬអ្នកមកពីក្រៅអាចមានសិទ្ធិចេញចូល និងធ្វើនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ហើយត្រូវធ្វើកិច្ចសន្យា និងត្រូវបង់កម្រៃ ចំនួន **២០០.០០០**រៀល (ម្ភៃម៉ឺនរៀល) ក្នុងមួយឆ្នាំ ព្រមទាំងគោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផល ដែលមិនមែនជាសមាជិកសហគមន៍នេសាទ មិនបានគោរពតាមប្រការនេះ គណៈកម្មការសហគមន៍នេសាទមានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់ជននោះ ហើយធ្វើការអប់រំណែនាំ ឬរាយការណ៍ជូនរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីអនុវត្តតាមច្បាប់ជាធរមាន។

**ប្រការ ៩.-**

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ត្រូវបានកែសម្រួល និងអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទ លើកដំបូង នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។

ថ្ងៃព្រហស្បតិ៍ ៥ រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
បូស្សីកែវ.ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៩
**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីថ្លែងការណ៍
# នៃការបង្កើតសហគមន៍នេសាទ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ឫស្សីកែវ |
| ភូមិ | ៖ | ឫស្សីកែវ ស្វាយជុំ បឹងរៃ និងស្រឡៅដំណាក់ |
| ឃុំ | ៖ | ឫស្សីកែវ |
| ស្រុក | ៖ | ព្រែកប្រសព្វ |
| ខេត្ត | ៖ | ក្រចេះ |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### សេចក្តីថ្លែងការណ៍
### នៃការបង្កើតសហគមន៍នេសាទឫស្សីកែវ

សហគមន៍នេសាទឫស្សីកែវ បានធ្វើមហាសន្និបាតលើកដំបូងរបស់សហគមន៍នេសាទ នៅឆ្នាំ២០១៨ និងបានបោះឆ្នោតឡើងវិញនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ ដែលមានអ្នកចូលរួមបោះឆ្នោត ចំនួន១១៧នាក់ ក្នុងនោះស្រីចំនួន២០នាក់ និងបានរៀបចំរចនាសម្ព័ន្ធសម្រាប់គ្រប់គ្រង និងដឹកនាំសហគមន៍នេសាទ មានគណៈកម្មការចំនួន ១១នាក់ ក្នុងនោះស្ត្រីចំនួន៣នាក់ ។

យើងខ្ញុំសូមជម្រាបជូនលោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ មេត្តាជ្រាបថា ការផ្តួចផ្តើមគំនិតបង្កើតសហគមន៍នេសាទឫស្សីកែវ ដោយមានសំណូមពរពីប្រជាពលរដ្ឋ ដែលកំពុងរស់នៅភូមិឫស្សីកែវ ស្វាយជុំ ស្រឡៅជំណាក់ និងភូមិបឹងរំ ឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ និងដោយមានគោលនយោបាយកែទម្រង់ស៊ីជម្រៅវិស័យជលផលរបស់រាជរដ្ឋាភិបាល នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១២។ បន្ទាប់ពីធ្វើមហាសន្និបាតលើកទី២របស់សហគមន៍នេសាទឫស្សីកែវរួចមក សមាជិកសហគមន៍នេសាទ និងគណៈកម្មការ អាជ្ញាធមូលដ្ឋានពាក់ពន្ធ័ និងខណ្ឌរដ្ឋបាលជលផលក្រចេះ រដ្ឋបាលជលផលថ្នាក់កណ្តាល បានសហការគ្នាចូលរួមប្រជុំពិគ្រោះយោបល់រៀបចំ៖

- បញ្ជីឈ្មោះសមាជិក និងគណៈកម្មការសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ
- រចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ផែនទីកន្លែងនេសាទសហគមន៍ មាត្រដ្ឋាន ១/៥០.០០០

កន្លែងនេសាទសហគមន៍ឫស្សីកែវ មានក្រឡាផ្ទៃទំហំ៩៥០,៨១ហិកតា និងមានកន្លែងអភិរក្សសហគមន៍នេសាទទំហំ១១ហិកតា។ សហគមន៍នេសាទឫស្សីកែវ គ្របដណ្តប់ទៅដោយធនធានធម្មជាតិ ជាច្រើនដូចជា មច្ឆជាតិ ព្រៃឈើ ព្រៃលិចទឹក វាលស្មៅ សត្វស្លាប ត្រីមេពូជ និងទេសភាពបឹង ។ មុនការធ្វើមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ធនធានទាំងនេះ មាននិន្នាការថយចុះជាលំដាប់ ដោយសារមិនមានការចូលរួមគ្រប់គ្រងការពារ និងការអភិរក្សធនធាន។

ដើម្បីដោះស្រាយបញ្ហានេះ អាជ្ញាធរភូមិ ឃុំ ស្រុក ខណ្ឌរដ្ឋបាលជលផលក្រចេះ រដ្ឋបាលជលផលថ្នាក់កណ្តាល គណៈកម្មការ និងសមាជិកសហគមន៍នេសាទឫស្សីកែវ បានសហការគ្នាបង្កើតជាសហគមន៍នេសាទស្រប តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ។

ការបង្កើតសហគមន៍នេសាទឫស្សីកែវក្នុងគោលបំណង៖

- ដើម្បីឱ្យប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋានចូលរួមគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព និងធានាការបែងចែកផលប្រយោជន៍លើធនធានជលផល ជូន សមាជិកសហគមន៍នេសាទប្រកបដោយសមធម៌

- ដើម្បីឱ្យប្រជាពលរដ្ឋក្នុងមូលដ្ឋាន បានដឹង និងទទួលស្គាល់កាន់តែច្បាស់នូវផលប្រយោជន៍ និងសារៈសំខាន់នៃធនធានជលផល ព្រមទាំងមានគំនិតចូលរួមគ្រប់គ្រង និងការពារធនធានជលផលក្នុងសហគមន៍នេសាទដោយផ្ទាល់
- ដើម្បីលើកស្ទួយកម្រិតជីវភាព របស់ប្រជាពលរដ្ឋក្នុងបណ្តាឃុំនៃសហគមន៍នេសាទ គណៈកម្មការ និងសមាជិកសហគមន៍នេសាទឫស្សីកែវ បានខិតខំចូលរួមគ្រប់គ្រង អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព ស្របតាមលិខិតបទដ្ឋានគតិយុត្តិនានា ដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ ព្រមទាំងខិតខំរៀនសូត្រ កសាងទំនាក់ទំនងជាមួយអង្គភាព ស្ថាប័នរដ្ឋ អង្គការដៃគូសប្បុរសជន ដើម្បីស្វែងរកអ្នកជួយឧបត្ថម្ភគាំទ្របច្ចេកទេស និងថវិកា សម្រាប់ដំណើការគ្រប់គ្រងរបស់សហគមន៍នេសាទ។ ចាប់តាំងពីបង្កើតសហគមន៍នេសាទក្នុងឆ្នាំ២០០៣ រហូតមកដល់សព្វថ្ងៃ គណៈកម្មការ និងសមាជិកសហគមន៍នេសាទ បានធ្វើការងារសំខាន់ៗ ដូចតទៅ៖
  - សហការយាមល្បាតនៅកន្លែងនេសាទសហគមន៍ និងកន្លែងអភិរក្សសហគមន៍នេសាទ
  - ទប់ស្កាត់ការពង្រីកដីកសិកម្មក្នុងកន្លែងនេសាទសហគមន៍
  - បទល្មើសនេសាទមានការថយចុះជាបន្តបន្ទាប់
  - បរិមាណផលត្រីក្នុងសហគមន៍នេសាទមានការគង់វង្ស ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ មេត្តាពិនិត្យ និងសម្រេចចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ឫស្សីកែវ ដើម្បីឱ្យសហគមន៍យើងខ្ញុំ បានទទួលស្គាល់តាមផ្លូវច្បាប់ដូចមានចែងក្នុងមាត្រា ២៤ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទដោយក្តីអនុគ្រោះ ។

ថ្ងៃអាទិត្យ ១២កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ឫស្សីកែវ ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២០

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**ឫស្សីកែវ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារផ្សេងៗ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ឫស្សីកែវ |
| ភូមិ | ៖ | ឫស្សីកែវ ស្វាយជុំ បឹងរ៉ៃ និងស្រឡៅដំណាក់ |
| ឃុំ | ៖ | ឫស្សីកែវ |
| ស្រុក | ៖ | ព្រែកប្រសព្វ |
| ខេត្ត | ៖ | ក្រចេះ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ០០៤ ប្រក.កសក

# ប្រកាស
## ស្តីពី
## ការចុះបញ្ជីសហគមន៍នេសាទចំនួន១១ នៅខេត្តស្វាយរៀង ត្បូងឃ្មុំ ក្រចេះ បន្ទាយមានជ័យ និងខេត្តពោធិ៍សាត់

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥អនក្រ.បក ចុះថ្ងៃទី២២ ខែសីហាឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ ក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ. ប ក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ ថ្មី នៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញប្រកាសលេខ៣១៦ ប្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

## សម្រេច

**ប្រការ ១.-**

ត្រូវបានចុះបញ្ជី និងទទួលស្គាល់ជាផ្លូវការដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នូវសហគមន៍នេសាទចំនួន១១ ដូចខាងក្រោម ៖

- ខេត្តស្វាយរៀង មានសហគមន៍នេសាទ ចំនួន០១ គឺសហគមន៍នេសាទបឹងដូនទយ
- ខេត្តត្បូងឃ្មុំ មានសហគមន៍នេសាទ ចំនួន០១ គឺសហគមន៍នេសាទពាមជីលាំង
- ខេត្តក្រចេះមានសហគមន៍នេសាទ ចំនួន០៣ គឺសហគមន៍នេសាទឬស្សីកែវ សហគមន៍នេសាទកោះសំ និងសហគមន៍នេសាទទំនប់ប៉ាក់
- ខេត្តបន្ទាយមានជ័យ មានសហគមន៍នេសាទ ចំនួន០៤ គឺសហគមន៍នេសាទថ្មមានជ័យ សហគមន៍នេសាទស្ទឹងកំបុតមានជ័យ សហគមន៍នេសាទទំនប់តាសោម និងសហគមន៍នេសាទអូរអន្លង់សំណរ
- ខេត្តពោធិ៍សាត់មានសហគមន៍នេសាទ ចំនួន០២ គឺសហគមន៍នេសាទអូរព្រះគង្គ និងសហគមន៍នេសាទអាងទឹកខ្លាក្រពើ។

ចំនួនសមាជិក ចំនួនសមាជិកគណៈកម្មការ ទំហំកន្លែងនេសាទសហគមន៍ ឈ្មោះភូមិ ឃុំ ស្រុក ខេត្ត និងនិយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នៃប្រកាសនេះ។

**ប្រការ ២.-**

ទំហំកន្លែងនេសាទសហគមន៍ និយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ដែលមានចែងក្នុងប្រការ១នៃប្រកាសនេះ អាចធ្វើការកែប្រែបានតាមការចាំបាច់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

អគ្គលេខាធិការ អគ្គាធិការ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពាក់ព័ន្ធ និងប្រធានគណៈកម្មការសហគមន៍នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សៅរ៍ ៤ កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តពាក់ព័ន្ធ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ ភ្ជាប់ប្រកាសលេខ......០០៤ ប្រក.កសក.ក......... ចុះថ្ងៃ..[illegible]................. ខែ..[illegible]..... ឆ្នាំ..[illegible]... ទោស័ក ព.ស២៥៦៤
ត្រូវនឹងថ្ងៃទី..១៦...... ខែ..មករា... ឆ្នាំ២០២១...របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

# សហគមន៍នេសាទក្នុងខេត្តស្វាយរៀង ត្បូងឃ្មុំ ក្រចេះ បន្ទាយមានជ័យ និងខេត្តពោធិ៍សាត់

| ល.រ | ឈ្មោះសហគមន៍នេសាទ | ចំនួនសមាជិក ប្រុស (ស្រី) | ចំនួនសមាជិកគណៈកម្មការសហគមន៍(ស្រី) | ទំហំផ្ទៃសហគមន៍ (ហិកតា) | ភូមិ | ឃុំ/សង្កាត់ | ស្រុក/ក្រុង | Projection :UTM, Everest 1830, Datum : Indian 1960, Zone : 48 N, Unit: Meter (X,Y) | (X,Y) |
|---|---|---|---|---|---|---|---|---|---|
| **១. ខេត្តស្វាយរៀង** | | | | | | | | | |
| ១ | បឹងជូនទយ | ៤៧៦ (១៥១) | ១១(0) | ៧៧១ | -បន្លាស្អិត<br>-ត្រពាំងធ្លក | ប្រេស | ចន្ទ្រា | A (615 627, 121 1412) | Y (615 750, 121 2100) |
| | | | | | | | | B (615 509, 121 1412) | Z (615 756, 121 2113) |
| | | | | | -ត្រពាំងបុណ្យ<br>-កោះគោ | ព្រៃគរគី | | C (615 423, 121 1346) | A1 (615 824, 121 2110) |
| | | | | | | | | D (615 248, 121 1331) | B1 (615 828, 121 2171) |
| | | | | | | | | E (615 330, 121 0989) | C1 (615 808, 121 2175) |
| | | | | | -តាប៉ោ<br>-សំឡីជើង<br>-ស្វាយចេក | សំឡី | កំពង់រោទ៍ | F (614 534, 121 0912) | D1 (615 814, 121 2212) |
| | | | | | | | | G (614 412, 121 1051) | E1 (615 899, 121 2200) |
| | | | | | | | | H (614 556, 121 1199) | F1 (615 900, 121 2126) |
| | | | | | | | | I (614 394, 121 1529) | G1 (615 933, 121 2124) |
| | | | | | | | | J (614 394, 121 1179) | H1 (615 935, 121 2107) |
| | | | | | | | | K (614 086, 121 1262) | I1 (616 077, 121 2111) |
| | | | | | | | | L (614 059, 121 2991) | J1 (616078, 121 2126) |
| | | | | | | | | M (613 336, 121 5177) | K1 (616 191, 121 2145) |
| | | | | | | | | N (612 756, 121 6149) | L1 (616 393, 121 2346) |
| | | | | | | | | O (613 305, 121 6157) | M1 (616 401, 121 2459) |
| | | | | | | | | P (613 731, 121 6494) | N1 (616 783, 121 2493) |
| | | | | | | | | Q (614 111, 121 5981) | O1 (616 749, 121 2191) |
| | | | | | | | | R (614 959, 121 4388) | P1 (617 030, 121 2422) |
| | | | | | | | | S (614 965, 121 2131) | Q1 (617 128, 121 2189) |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | T (615 372, 1212122)<br>U (615 579, 121 2015)<br>V (615 662, 121 1927)<br>W (615 790, 121 1950)<br>X (615 799, 121 2048) | $R_1$ (617 049, 121 1149)<br>$S_1$ (617 081, 121 0671)<br>$T_1$ (616 808, 121 0558)<br>$U_1$ (616 360, 121 1647)<br>$V_1$ (615 696, 121 1446) |
| ២. ខេត្តត្បូងឃ្មុំ | | | | | | | | | |
| ១ | ពាមជីលាំង | ១៦៥ (៩៤) | ១១ (៣) | ១ ៥៥៤ | -ពាមក្នុង<br>-ព្រែកពាម<br>-ព្រែកផ្ដៅ<br>-កំពង់ចន្លុះលិច<br>-កំពង់ចន្លុះកើត<br>-តាប៉ាង<br>-បទស្លាស្នាប | ពាមជីលាំង | ត្បូងឃ្មុំ | A (560 438, 133 3881)<br>B (559 572, 133 5074)<br>C (559 572, 133 7612)<br>D (560 002, 133 7712)<br>E (550 021, 133 7658)<br>F (565 354, 134 1700)<br>G (567 859, 134 0600) | H (567 549, 133 8835)<br>I (567 924, 133 7295)<br>J (567 530, 133 5999)<br>K (565 694, 133 8122)<br>L (564 093, 133 8579)<br>M (562 948, 134 0096)<br>N (560 043, 133 7603) |
| ៣. ខេត្តក្រចេះ | | | | | | | | | |
| ១ | ឫស្សីកែវ | ២០២ (៥៧) | ១១ (៣) | ៩៥០,៨១ | -ឫស្សីកែវ<br>-ស្វាយជុំ<br>-ស្រឡៅដំណាក់<br>-បឹងរៃ | ឫស្សីកែវ | ព្រែកប្រសព្វ | A (584525, 135 9925)<br>B (583 675, 135 9585)<br>C (582 666, 135 9065)<br>D (582 172, 135 9385)<br>E (582 388, 135 9853)<br>F (582 748, 136 0489)<br>G (583 225, 136 0541)<br>H (583 565, 136 0588)<br>I (586 316, 135 8831)<br>J (586 009, 135 9083)<br>K (585 931, 135 9442)<br>L (585 605, 135 9638) | N (586 276, 136 2418)<br>O (587 019, 136 1161)<br>P (587 415, 136 0078)<br>Q (587 186, 135 8943)<br>R (584 032, 136 1151)<br>S (584 501, 136 0431)<br>T (584 757, 135 9808)<br>U (584 309, 135 9379)<br>V (583 482, 135 8818)<br>w (583 433, 135 8818)<br>X (584 291, 135 9419)<br>Y (584 694, 135 9808) |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | M (584 311, 136 1144)<br>N (586 276, 136 2418) | Z (584 475, 136 0375)<br>$A_1$ (583 988, 136 1118) |
| ២ | កោះសំ | ៧៤ (៤២) | ១១ (៣) | ៦១៨ | កោះសំ | សំបូរ | សំបូរ | A (604 608, 140 9545)<br>B (607 276, 140 7281)<br>C (606 691, 140 6955) | D (606 534, 140 6868)<br>E (605 459, 140 6268)<br>F (603 610, 140 9549) |
| ៣ | ទំនប់ប៉ាក់ | ១១០ (៦៧) | ៧ (២) | ១១១ | កែងប្រាសាទ | សំបូរ | សំបូរ | A (607 888, 141 0211)<br>B (607 609, 141 0200)<br>C (607 281, 141 1152)<br>D (607 181, 141 1156)<br>E (607 018, 141 1617)<br>F (606 978, 141 1804) | G (607 102, 141 2105)<br>H (607 407, 141 2595)<br>I (607 651, 141 2659)<br>J (607 504, 141 1641)<br>K (607 745, 141 1566) |
| **៣. ខេត្តបន្ទាយមានជ័យ** | | | | | | | | | |
| ១ | ថ្មមានជ័យ | ៤០០ (២១៨) | ៩ (២) | ២ ០៣៥ | -ថ្មដប់<br>-ចែកអង្ករ | សំបូរ | មង្គលបូរី | A (311 734, 148 6272)<br>B (311 558, 147 9989)<br>C (307 589, 148 0387)<br>D (307 301, 148 2667) | E (307 381, 148 3993)<br>F (307 497, 148 5951)<br>G (309 833, 148 5155)<br>H (311 534, 148 6015) |
| ២ | ស្ទឹងកំបុតមានជ័យ | ១៦១ (៩៣) | ៧(២) | ២ ៦៦០ | ស្ទឹងកំបុត | រហាល | ព្រះនេត្រព្រះ | A (310 000, 150 1000)<br>B (310 212, 149 3939)<br>C (308 522, 149 1909)<br>D (305 230, 149 4080) | E (306 700, 149 4678)<br>F (306 906, 149 6245)<br>G (307 142, 149 8181)<br>H (308 501, 150 1704) |
| ៣ | ទំនប់តាសោម | ៥៦០ (២៧៩) | ៧(០) | ៦ ៧០០ | -កំពង់ក្រសាំង<br>-កាបៅ<br>-ភ្នំលៀប | ភ្នំលៀប | ព្រះនេត្រព្រះ | A (312 308, 148 0060)<br>B (311 881, 148 6267)<br>C (314 074, 148 8099)<br>D (312 475, 149 2775)<br>E (313 352, 149 0550)<br>F (314 178, 149 0553) | G (315 561, 149 2126)<br>H (316 636, 149 6010)<br>I (318 131, 148 9819)<br>J (317 773, 148 7980)<br>K (317 616, 148 6191)<br>L (318 181, 147 9781) |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៤ | អូរអន្លង់សំណារ | ៣១៤ (១៦៨) | ៧ (២) | ៦២,២ | ប៉ោយអង្គរ | តាគង់ | ម៉ាឡៃ | A (262 268, 149 2055)<br>B (262 067, 149 2071)<br>C (261 514, 149 1436) | D (260 023, 149 1275)<br>E (259 920, 149 1092)<br>F (261 454, 149 1654) |
| **៣. ខេត្តពោធិ៍សាត់** | | | | | | | | | |
| ១ | អូរព្រះគង្គ | ៣៧២ (១៨៥) | ១១ (២) | ៦៧,៨៥ | -កំពង់ស្វាង<br>-អូររការ | ចំរើនផល | ពោធិ៍សាត់ | A (375 485, 138 0879)<br>B (375 439, 138 0880)<br>C (375 493, 137 9656)<br>D (374 006, 137 7969)<br>E (373 840, 137 7320) | F (373 181, 137 7060)<br>G (374 169, 137 6668)<br>H (373 978, 137 7277)<br>I (374 081, 137 7967)<br>K (375 572, 137 9658) |
| ២ | អាងទឹកខ្លាក្រពើ | ២០៣ (៧៦) | ១១ (៤) | ១១ | ខ្លាក្រពើ | អន្លង់ត្នោត | ក្រគរ | A (412 002, 137 9362)<br>B (411 943, 137 9577)<br>C (412 059, 137 9732) | D (412 241, 137 9613)<br>E (412 285, 137 9412) |

**បានឃើញនិងឯកភាព**

ថ្ងៃ ៣ កើត ៨ កោត ខែ មិគសិរ ឆ្នាំ ឆ្លូវ ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### សូមគោរពជូន
### លោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ

**កម្មវត្ថុ** ៖ សំណើសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ឫស្សីកែវ ។

**យោង** ៖- អនុក្រឹត្យ លេខ២៥ អនក្រ. បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ

- មហាសន្និបាតលើកទី២ របស់សហគមន៍នេសាទធ្វើនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩។

**លិខិតភ្ជាប់** ៖ កម្មវិធីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ឫស្សីកែវ ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ យោង និងលិខិតភ្ជាប់ខាងលើ យើងខ្ញុំសូមជម្រាបជូនលោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ មេត្តាជ្រាបថា សហគមន៍នេសាទឫស្សីកែវ បានបង្កើតឡើងដោយស្ម័គ្រចិត្ត និងមានគំនិតផ្ដួចផ្ដើម បង្កើនជីវភាពរស់នៅ របស់ប្រជាពលរដ្ឋក្នុង ភូមិឫស្សីកែវ ស្វាយជុំ ស្រឡៅជំណាក់ និងភូមិបឹងរៃ ឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។ ចាប់តាំងពីធ្វើមហាសន្និបាតលើកដំបូងរបស់សហគមន៍នេសាទឫស្សីកែវ គណៈកម្មការសហគមន៍ និងសមាជិកសហគមន៍នេសាទ បានចូលរួមអនុវត្តន៍ការងារយ៉ាងសកម្មជាមួយខណ្ឌរដ្ឋបាលជលផលក្រចេះ រដ្ឋបាលជលផលថ្នាក់កណ្ដាល និងអាជ្ញាធរដែនដី ។

លទ្ធផលទទួលបានគួរឱ្យមានការកត់សំគាល់មានដូចជា៖

- បញ្ជីឈ្មោះគណៈកម្មការ និងសមាជិកសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ
- វចនាសម្ព័ន្ធរបស់គណៈសហគមន៍នេសាទ
- ផែនទីកន្លែងនេសាទសហគមន៍ មាត្រដ្ឋាន ១/៥០.០០០
- កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- សហការយាមល្បាតកន្លែងនេសាទសហគមន៍ និងកន្លែងអភិរក្សសហគមន៍នេសាទ
- ចូលរួមបង្ក្រាបបទល្មើសនេសាទ និងទប់ស្កាត់ការពង្រីកដីកសិកម្ម
- ការពារព្រៃលិចទឹក ។

យោងតាមសកម្មភាពនិងលទ្ធផលដែលទទួលបាន ប្រធានគណៈកម្មការសហគមន៍នេសាទឫស្សីកែវ សូមស្នើចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ឫស្សីកែវ ជាមួយលោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ។

អាស្រ័យហេតុនេះ សូមលោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះ មេត្តាពិនិត្យលើលទ្ធភាព និងរៀបចំកម្មវិធីចុះកិច្ចព្រមព្រៀងកន្លែងនេសាទ សហគមន៍ឫស្សីកែវ តាមការស្នើសុំខាងលើ ព្រមទាំងផ្ដល់ការគាំទ្រដល់សហគមន៍នេសាទរបស់យើងខ្ញុំ ដើម្បីគ្រប់គ្រង ធនធានជលផល និងប្រើប្រាស់ធនធានជលផលក្នុងតំបន់ឱ្យទទួលបានជោគជ័យ សម្រាប់កូនចៅជំនាន់ក្រោយ។

សូមលោកនាយខណ្ឌរដ្ឋបាលជលផល មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ ។

ថ្ងៃព្រហស្បតិ៍ ១៤ កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ឫស្សីកែវ ថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០

**ប្រធានគណៈកម្មការសហគមន៍នេសាទឫស្សីកែវ**

[signature]

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុស្តីពី

ការប្រជុំពិភាក្សារៀបចំ និងចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ឫស្សីកែវ
នៅឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ

ឆ្នាំពីរពាន់ម្ភៃ ខែមីនា ថ្ងៃទីប្រាំ វេលាម៉ោងប្រាំបី និងសាបសិបនាទីព្រឹក នៅសាលាឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ មានបើកកិច្ចប្រជុំមួយដោយមានសមាជិក និងគណៈកម្មការសហគមន៍នេសាទ ឫស្សីកែវអាជ្ញាធរដែនដី អ្នកសម្របសម្រួលមកពីរដ្ឋបាលជលផល ខណ្ឌរដ្ឋបាលជលផលក្រចេះ ដើម្បីពិភាក្សារៀបចំ និងចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ឫស្សីកែវ ក្រោមអធិបតីភាពលោក **ម៉ែន អ៊ុក** មេឃុំឫស្សីកែវ ជាប្រធានអង្គប្រជុំ ដោយមានសមាសភាពអញ្ជើញចូលរួមដូចខាងក្រោម ÷

១ - លោក សៀន គិន នាយខណ្ឌរដ្ឋបាលជលផលក្រចេះ

២ - លោក ម៉ែន អ៊ុក មេឃុំឫស្សីកែវ

៣ - លោក បែន ប៊ុណ្ណាវ៉ារុធ នាយផ្នែករដ្ឋបាលជលផលព្រែកប្រសព្វ

៤ - លោក មុំ អួយ មេភូមិស្វាយជុំ

៥ - លោក ងិន ចាន់ថន មេភូមិឫស្សីកែវ

៦ - លោក តាំ សមយ័ មេភូមិស្រឡៅជំណាក់

៧ - លោក កាំង ប៊ុង មេភូមិបឹងរៃ

៨ - លោកស្រី ហុក កយ ប្រធានសហគមន៍នេសាទឫស្សីកែវ

៩ - បញ្ជីវត្តមានគណៈកម្មការ និងសមាជិកសហគមន៍នេសាទឫស្សីកែវ អញ្ជើញចូលរួម

របៀបវារៈ

១ - ប្រកាសហេតុនិងប្រកាសគណៈអធិបតី

២ - អញ្ជើញលោកមេឃុំឫស្សីកែវឡើងមានមតិស្វាគមន៍ និងបើកកម្មវិធី

៣- អញ្ជើញលោកនាយខណ្ឌរដ្ឋបាលជលផលក្រចេះឡើងមានមតិ

៤- អញ្ជើញប្រធានគណៈកម្មការសហគមន៍នេសាទឫស្សីកែវឡើងមានមតិ

៥- សរុបលទ្ធផល មតិផ្តាំផ្ញើ និងបិទកម្មវិធី

ជាកិច្ចចាប់ផ្តើមអ្នកកាន់កម្មវិធីបានមានមតិស្វាគមន៍ចំពោះគណៈអធិបតី គណៈកម្មការ និងសមាជិកសហគមន៍នេសាទឫស្សីកែវ និងអ្នកចូលរួមទាំងអស់។ បន្ទាប់មក ការប្រកាសហេតុ ប្រកាសគណៈអធិបតី ជម្រាបជូនអង្គប្រជុំអំពីរបៀបវារៈនៃកិច្ចប្រជុំ និងការអញ្ជើញវាគ្មិនឡើងមានមតិ ។

លោក **ម៉ែន អ៊ុក** មេឃុំឫស្សីកែវ បានឡើងមានមតិស្វាគមន៍ និងលើកឡើងពីស្ថានភាពភូមិសាស្ត្រ នៃកន្លែងនេសាទសហគមន៍ឫស្សីកែវ និងសកម្មភាពការងារដែលបានអនុវត្តកន្លងមករបស់សហគមន៍នេសាទ ក្នុងគោលដៅ

គ្រប់គ្រង ការពារ ថែរក្សាធនធានធម្មជាតិឱ្យស្ថិតនៅបានគង់វង្សយូរអង្វែង ដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋ ក្នុងមូលដ្ឋាន ព្រមទាំងការប្រកាសបើកកិច្ចប្រជុំពិភាក្សារៀបចំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ឫស្សីកែវចាប់ពីពេលនេះទៅ។

បន្ទាប់មកទៀត ដំណើរការពិភាក្សា រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ឫស្សីកែវ ដោយផ្អែកលើគំរូនៃប្រកាស ស្តីពី គោលការណ៍ណែនាំអំពីសហគមន៍នេសាទ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខៈ៣១៦ ប្រក. កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧។

ជាលទ្ធផលកិច្ចប្រជុំពិភាក្សាទាំងមូលបានផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក និងបានឯកភាពគ្នាជាឯកច្ឆន្ទតាមលំដាប់លំដោយដូចខាងក្រោមៈ

- នាយខណ្ឌរដ្ឋបាលជលផលក្រចេះ ជាតំណាងស្របច្បាប់ នៃរដ្ឋបាលជលផល មានអាសយដ្ឋាន នៅភូមិក្រចេះ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ទូរស័ព្ទលេខ: ០៩២ ៥៨៨ ៨២៨ ហៅថា "ភាគីក" ។ ប្រធានគណៈកម្មការសហគមន៍នេសាទឫស្សីកែវ ជាតំណាងស្របច្បាប់ឱ្យសហគមន៍នេសាទ ដែលមានអាសយដ្ឋានស្ថិតនៅភូមិឫស្សីកែវ ឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ទូរស័ព្ទលេខ: ០៩២ ២៤៦ ៥៧១ ហៅថា "ភាគីខ" ។

- ប្រការ ១.- ភាគី ក ប្រគល់ដែននេសាទ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ឱ្យភាគី ខ ធ្វើការគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍ និងប្រើប្រាស់ធនធានជលផល រយៈពេល៣ឆ្នាំ ចាប់ពីថ្ងៃទី០៥ ខែមិនាឆ្នាំ២០២០ រហូតដល់ថ្ងៃ ទី០៥ ខែមិនា ឆ្នាំ២០២២ ដោយធានានូវចីរភាពតាមរយៈការរៀបចំសហគមន៍នេសាទ។

- ប្រការ ២.-ដែននេសាទនេះ មានឈ្មោះថា កន្លែងនេសាទសហគមន៍ឫស្សីកែវ ដែលលាតសន្ធឹង នៅក្នុងភូមិឫស្សីកែវ ភូមិស្វាយជុំ ភូមិស្រឡៅដំណាក់ និងភូមិបឹងវែ ឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះៈ

- ខាងកើតទល់នឹងភូមិចំបក់២ ឃុំចំបក់ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ
- ខាងលិចទល់នឹងភូមិខ្ពបតាងួន ឃុំខ្ពបតាងួន ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម
- ខាងត្បូងទល់នឹងឃុំរកាខ្ពស់ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ
- ខាងជើងទល់នឹងចំណុចស្រែឆ្នាប ភ្នំឆ្មោត ភូមិឫស្សីកែវ ឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។

មាននិយាមកាដូចខាងក្រោមៈ

(Datum: indian_1960_ UTM Zone 48N)

ID X Y ចំណុចគោលដៅ

**និយាមកាបឹងវែង:**

| | X | Y | |
|---|---|---|---|
| ១- | 586316 | 1358831 | ដើមត្រសេកក្បែរផ្លូវ ខាងលិចផ្លូវចុះទៅចុងទួល កែងដីស្រែ ឈ្មោះស្រឿន នៅភូមិឫស្សីកែវ |
| ២- | 586009 | 1359083 | ដើមរាំងខាងលិចច្រកច្រកែង កែងនឹងចុងដីស្រែឈ្មោះហេង ប្រពន្ធឈ្មោះវន នៅភូមិឫស្សីកែវ |
| ៣- | 585931 | 1359442 | ដើមរាំងច្រករោងចាម កែងចុងដីស្រែឈ្មោះ មាន នៅភូមិឫស្សីកែវ |
| ៤- | 585605 | 1359638 | ដើមរាំងច្រកថ្មោម ចុងដីស្រែឈ្មោះ តា វ៉ាន់ នៅភូមិឫស្សីកែវ |
| ៥- | 584923 | 1359768 | ជ្រោយព្រៃខាងលិច ពយបឹងវែង |
| ៦- | 584311 | 1361144 | ដើមត្រសេកធំ ចុងដីស្រែឈ្មោះ វី នៅភូមិស្រឡៅដំណាក់ |
| ៧- | 586276 | 1362418 | ច្រកភ្នំឆ្មោត ចុងស្ទឹង |
| ៨- | 587019 | 1361161 | ដើមពពូលធំ ជ្រោយចង្អឹង ខាងកើតបឹងវែង |

៩- 587415 - 1360078 ផ្ទាំងថ្ម ក្រោមដើមត្រសេកធំ ជ្រោយតាចក់ ខាងកើតបឹងវែង
១០- 587186 - 1358943 ដើមរាំងធំ២ដើម ចុងដីស្រែឈ្មោះ ណាល់ វ៉ន នៅភូមិស្វាយជុំ ។

**និយាមការកន្លែងអភិរក្សត្រីមេពូជ:**

X Y ចំណុចគោលដៅ

១ - 586731 - 1359785 បង្គោលកែងខាងជើង ឈៀងខាងកើតកន្លែងអភិរក្ស
២ - 586646 - 1359407 បង្គោលកែងខាងកើត ឈៀងខាងត្បូងកន្លែងអភិរក្ស
៣ - 586383 - 1359395 បង្គោលកែងខាងត្បូងឈៀងខាងលិចកន្លែងអភិរក្ស
៤ - 586441 - 1359801 បង្គោលកែងខាងលិចឈៀងខាងជើងកន្លែងអភិរក្ស។

**និយាមការបឹងកាហាត:**

X Y ចំណុចគោលដៅ

១ - 584525 - 1359925 ដើមត្រស់កំពង់ទូកតាជីន
២ - 583675 - 1359585 ដើមរាំងកំពង់ទូកតាប្រុក
៣ - 582666 - 1359065 ដើមរាំងមាត់ប្រឡាយស្ថានីយ៍បូមទឹកក្រោយវត្តបឹងរ៉ៃ
៤ - 582172 - 1359385 ដើមរាំងខាងលិចឈៀងខាងត្បូងបឹងកាហាត ចុងដីស្រែឈ្មោះ តា ទុយ នៅភូមិបឹងរ៉ៃ
៥ - 582388 - 1359853 ដើមជាលាខាងលិច ឈៀងខាងជើងបឹងកាហាត( ចំណុចក្នុងព្រៃលិចទឹកជ្រៅ ឆ្ងាយផុតពីក្បាលដីចំការរបស់ប្រជាពលរដ្ឋ)
៦ - 582748 - 1360489 ដើមជាលាខាងជើងឈៀងខាងលិចបឹងកាហាតចុងដីស្រែឈ្មោះ តា ជូ នៅភូមិបឹងរ៉ៃ
៧ - 583225 - 1360541 ចម្ងាយប្រមាណ៥ម ខាងត្បូងដើមជាលាមាត់ប្រឡាយទំនប់បឹងកាហាត ចុងដីស្រែឈ្មោះ ពិសិដ្ឋ នៅភូមិស្រឡៅដំណាក់
៨ - 583565 - 1360588 ដើមរាំងនៅក្បែរផ្លូវ ទៅកំពង់ចុះទូកបឹងកាហាត ចុងដីស្រែឈ្មោះ ម៉ាប់ នៅភូមិស្រឡៅដំណាក់

**និយាមការប្រឡាយអូរជង:**

X Y ចំណុចគោលដៅ

៩ - 584032 - 1361151 ខាងកើតមាត់ប្រឡាយអូរជងចំណុចព្រំប្រទល់ខេត្តក្រចេះ កំពង់ចាម
១០ - 584501 - 1360431ខាងជើងមាត់ប្រឡាយអូរជង ខាងលិចកោងប្រឡាយអូរជង
១១ - 584757 - 1359808 ទល់មុខឬទន្ទឹមនឹងបង្គោលទី២៦ ខាងកើតប្រឡាយអូរជង
១២ - 584309 - 1359379 ទល់មុខឬទន្ទឹមនឹងបង្គោលទី២៥ ខាងត្បូងប្រឡាយអូរជង
១៣ - 583482 - 1358818 ដើមរាំងខាងកើត ក្បាលប្រឡាយអូរជងខាងលិចជួរដើមត្នោតភូមិស្រឡៅដំណាក់
១៤ - 583433 - 1358818 ចម្ងាយ៥៣មខាងលិចបង្គោលទី១ខាងលិចជួរដើមត្នោតនៅភូមិស្រឡៅដំណាក់
១៥ - 584291 - 1359419 ដើមរាំងខាងជើងប្រឡាយអូរជង ចុងដីស្រែឈ្មោះ តា ឈុំ នៅភូមិស្រឡៅដំណាក់
១៦ - 584694 - 1359808 ដើមសណ្តាន់ខាងលិចប្រឡាយអូរជងមុខដីស្រែឈ្មោះគៀត ស៊ីយាងនៅភូមិបឹងរ៉ៃ
១៧ - 584475 - 1360375 ខាងត្បូងមាត់ប្រឡាយអូរជង ខាងលិចកោងអូរជង
១៨ - 583988 - 1361118 ខាងលិចមាត់ប្រឡាយអូរជង ចំណុចព្រំប្រទល់ខេត្តក្រចេះ កំពង់ចាម។

- ប្រការ ៣ រហូតដល់ប្រការ ១២ ភាគីទាំង២បានឯកភាពគ្នាយកតាម កិច្ចព្រមព្រៀងដូចមានក្នុង ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ របស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ។

កិច្ចបញ្ចប់ ភាគីទាំង២បានឯកភាពគ្នា ចុះហត្ថលេខាលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ឬស្សីកែវ នៅចំពោះមុខអ្នកចូលរួមទាំងអស់ ដោយមានលោកមេឃុំឬស្សីកែវធ្វើជាសាក្សី។

លោក **ម៉ែន អ៊ុក** មេឃុំឬស្សីកែវ បានបូកសរុបលទ្ធផលនៃកិច្ចប្រជុំពិភាក្សារៀបចំ និងចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ឬស្សីកែវ និងការប្រកាសបិទកម្មវិធី ។

កំណត់ហេតុ បានបញ្ចប់ចប់សព្វគ្រប់ នៅវេលា ម៉ោងដប់មួយ និងសាមសិបនាទី នាថ្ងៃ ខែ ឆ្នាំដដែល ប្រកបដោយភាពរលូន និងទទួលបានលទ្ធផលល្អ។

**អ្នកធ្វើកំណត់ហេតុ**

**បានឃើញនិងឯកភាព**
**ប្រធានអង្គប្រជុំ**

ម៉ែន អ៊ុក

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### កំណត់ហេតុ
### ស្តីពី
### ការប្រជុំផ្សព្វផ្សាយសេចក្តីព្រាងផែនទីកន្លែងនេសាទសហគមន៍ឫស្សីកែវ នៅសាលាឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ

ឯកស័ក ពុទ្ធសករាជ ពីរពាន់ប្រាំរយហុកសិបបី ឆ្នាំកុរ ខែជេស្ឋ ថ្ងៃពុធ ដប់កើត ត្រូវនឹងឆ្នាំពីរពាន់ដប់ប្រាំបួន ខែមិថុនា ថ្ងៃទីដប់ពីរ វេលាម៉ោងប្រាំបី និងដប់នាទីព្រឹក នៅសាលាឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ មានបើកកិច្ចប្រជុំមួយ ដោយមានការចូលរួមពីសមាជិក និងគណៈកម្មការសហគមន៍នេសាទឫស្សីកែវ អាជ្ញាធរភូមិពាក់ព័ន្ធ ឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ រដ្ឋបាលបាលជលផល(ខណ្ឌរដ្ឋបាលជលផលក្រចេះ ផ្នែករដ្ឋបាលជលផលព្រែកប្រសព្វ) និងចាស់ព្រឹទ្ធាចារ្យ ដើម្បីប្រជុំធ្វើការផ្សព្វផ្សាយផែនទីកន្លែងនេសាទសហគមន៍ឫស្សីកែវ ក្រោមអធិបតីភាពលោក **ត្រាក់ ផល្លី** មន្ត្រីរដ្ឋបាលសាលាស្រុកព្រែកប្រសព្វ ជាតំណាងអភិបាលនៃគណៈអភិបាលស្រុកព្រែកប្រសព្វ និងលោក **សៀន គិន** នាយខណ្ឌរដ្ឋបាលជលផលក្រចេះ តំណាងរដ្ឋបាលជលផល ដោយមានសមាសភាពអញ្ជើញចូលរួមដូចខាងក្រោម៖

| | |
|---|---|
| ១- លោក ប៉ែន ប៊ុណ្ណារ៉ាវុធ | នាយផ្នែករដ្ឋបាលជលផលព្រែកប្រសព្វ |
| ២- លោក ម៉ែន អ៊ុក | មេឃុំឫស្សីកែវ |
| ៣- លោក មុំ អួយ | មេភូមិស្វាយជុំ |
| ៤- លោក គឹម ស្រិហ៍ | មេភូមិឫស្សីកែវ |
| ៥- លោក អ៊្លឹង ប៊ុនរិទ្ធ | អនុមេភូមិស្រឡៅដំណាក់ |
| ៦- លោក កាំង ប៊ុង | មេភូមិបឹងវែ |
| ៧- លោកស្រី ហុក កយ | ប្រធានសហគមន៍នេសាទឫស្សីកែវ |
| ៨- លោក អ៊ុក ធីរ៉ា | ទីប្រឹក្សាសហគមន៍នេសាទថ្នាក់ខេត្ត គម្រោង M-IWRM-P3 |

៩- បញ្ជីវត្តមានគណៈកម្មការ និងសមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធអញ្ជើញចូលរួម

ជាកិច្ចចាប់ផ្តើមកម្មវិធីលោក **ម៉ែន អ៊ុក** បានមានមតិស្វាគមន៍ចូលរួម ដោយលើកឡើងយកពីផែនទីព្រាងកន្លែងនេសាទសហគមន៍ឫស្សីកែវ ដែលក្រុមការងារចម្រុះ បានចុះកំណត់និយាមកាចំណុចនៅបឹងកាហាត អូរជង និងបឹងវែង កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ និងថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៩ ដើម្បីជម្រាបជូនដល់អង្គប្រជុំទាំងមូលបានជ្រាប ។ ពាក់ព័ន្ធនឹងការប្រជុំផ្សព្វផ្សាយផែនទីកន្លែងនេសាទសហគមន៍ឫស្សីកែវនៅថ្ងៃនេះ លោកមេឃុំ បានស្នើសុំឱ្យ លោកមេភូមិ លោកអនុភូមិ និងអ្នកពាក់ព័ន្ធទាំងអស់ ដែលមានវត្តមានក្នុងអង្គប្រជុំ ជួយផ្តល់ព័ត៌មានទាក់ទងនឹងផែនទីព្រាងនេះ ឱ្យបានទូលំទូលាយ ដល់បងប្អូនប្រជាពលរដ្ឋ ដែលមានដីស្រែ ដីចំការ ស្ថិតនៅជាប់មាត់បឹង ដើម្បីឱ្យពួកគាត់ អញ្ជើញមកចូលរួមពិនិត្យ ផ្ទៀងផ្ទាត់ថា តើការកំណត់និយាមកាផែនទីនេះ បានធ្វើឱ្យប៉ះពាល់ដល់ដីស្រែ ដីចំការ របស់ពួកគាត់ដែរឬទេ ?

បន្ទាប់មកលោក **សៀន គិន** នាយខណ្ឌរដ្ឋបាលជលផលក្រចេះ និងជាប្រធានគម្រោងគ្រប់គ្រងធនធានទឹកចម្រុះថ្នាក់ខេត្ត បានមានមតិស្វាគមន៍បើកអង្គប្រជុំ និងបានលើកឡើងពីប្រវត្តិនៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះ ដែលបានទទួល

ហិរញ្ញប្បទានពីធនាគារពិភពលោក និងសកម្មភាពចម្បងៗទាំង៣ផ្នែក ដែលគម្រោងបាន និងកំពុងអនុវត្ត ព្រមទាំងសមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបាននាពេលកន្លងមក ដើម្បីជម្រាបជូនដល់អ្នកចូលរួមទាំងអស់បានជ្រាប ។ ពាក់ព័ន្ធនឹងការប្រជុំផ្សព្វផ្សាយផែនទីព្រាងកន្លែងនេសាទសហគមន៍ឫស្សីកែវនេះវិញ លោកប្រធានគម្រោងថ្នាក់ខេត្ត បានមានមតិបញ្ជាក់ថា កាលពីចុងខែមេសា និងដើមខែឧសភា ឆ្នាំ២០១៩កន្លងទៅ ក្រុមការងារចម្រុះចុះធ្វើផែនទីកន្លែងនេសាទសហគមន៍ មាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទនៃរដ្ឋបាលជលផល ខណ្ឌរដ្ឋបាលជលផលក្រចេះ ក្រុមប្រឹក្សាឃុំឫស្សីកែវ លោកមេភូមិពាក់ព័ន្ធ និងសហគមន៍នេសាទឫស្សីកែវ បានចុះកំណត់និយាមកានៅបឹងកាហាត អូរជង បឹងវែង និងកន្លែងអភិរក្សត្រីមេពូជ ហើយទិន្នន័យចំណុចនិយាមកាទាំងអស់នេះ ត្រូវបានលោក**ស៊ូ ហឫត្រា** អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទនៃរដ្ឋបាលជលផល បញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីផលិតចេញជាផែនទីព្រាងមានទំហំសរុប៩៥០,៨១ហ.ត ហើយក្នុងនោះកន្លែងអភិរក្សត្រីមេពូជក្នុងបឹងវែងមានទំហំ១១ហ.ត ដូចដែលយើងទាំងអស់គ្នា បានឃើញនៅថ្ងៃនេះ ។ ក្នុងឱកាសនោះ លោកប្រធានគម្រោង បានមានមតិបញ្ជាក់បន្ថែមថា គោលបំណងនៃការប្រជុំផ្សព្វផ្សាយ ផែនទីព្រាងកន្លែងនេសាទសហគមន៍ឫស្សីកែវនេះ គឺដើម្បីពិនិត្យផ្ទៀងផ្ទាត់ថា តើចំណុចនិយាមកាណាខ្លះដែលធ្វើឱ្យប៉ះពាល់ដល់ដីស្រែ និងដីចំការ របស់កសិករយើង ? ។ បន្ទាប់ពីការប្រជុំផ្សព្វផ្សាយនៅសាលាឫស្សីកែវនេះរួច យើងនឹងធ្វើការបិទផ្សព្វផ្សាយនៅសាលាឃុំ នៅតាមទីប្រជុំជននានា និងនៅតាមភូមិទាំង៤(ស្វាយជុំ ឫស្សីកែវ ស្រឡៅដំណាក់ បឹងរ៉ៃ) ក្នុងរយៈពេលសាបសិបថ្ងៃ ដើម្បីទុកពេលវេលានេះឱ្យប្រជាពលរដ្ឋដែលមានដីស្រែ ដីចំការពាក់ព័ន្ធធ្វើការតវ៉ា ។ ផុតកំណត់រយៈពេលបិទផ្សាយនេះ ខណ្ឌរដ្ឋបាលជលផលក្រចេះ នឹងស្នើសុំទៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទនៃរដ្ឋបាលជលផល ឱ្យជួយរៀបចំផែនទីផ្លូវការមកខណ្ឌរដ្ឋបាលជលផលក្រចេះ ដើម្បីចុះហត្ថលេខាតាមលំដាប់លំដោយពីថ្នាក់ក្រោមទៅថ្នាក់លើ ពោលគឺពីសហគមន៍នេសាទដល់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

បន្ទាប់មកទៀត លោក **ត្រក់ ផល្លី** មន្ត្រីរដ្ឋបាលស្រុកព្រែកប្រសព្វ ជាតំណាងលោកអភិបាលនៃគណៈអភិបាលស្រុកព្រែកប្រសព្វ បានមានមតិឯកភាពទៅនឹងការលើកឡើងរបស់លោកប្រធានគម្រោងខាងលើ ហើយលោកបានស្នើសុំឱ្យក្រុមប្រឹក្សាឃុំ លោកមេភូមិ អនុភូមិ សហគមន៍នេសាទ និងបងប្អូនប្រជាពលរដ្ឋយើង ដែលបានស្គាល់ឈ្មោះម្ចាស់ដីស្រែ ដីចំការដែលជាប់ពាក់ព័ន្ធនឹងនិយាមកាផែនទីនេះ សូមកុំភ្លេចប្រាប់ទៅពួកគាត់ ឱ្យអញ្ជើញមកពិនិត្យផ្ទៀងផ្ទាត់មើលនៅលើផែនទីនេះ ក្រែងមានចំណុចណាមិនប្រក្រតីត្រូវកែតម្រូវ ។ លោកត្រក់ ផល្លី បានមានមតិបញ្ជាក់ថាគ្រប់ទីកន្លែងដែលបិទផ្សាយផែនទីព្រាងកន្លែងនេសាទសហគមន៍ឫស្សីកែវនេះ ត្រូវមានអ្នកទទួលបន្ទុកពិគ្រោះយោបល់ជាមួយបងប្អូនប្រជាពលរដ្ឋដែលមានបណ្ដឹងតវ៉ា ឬ សរសេរលេខទូរស័ព្ទដាក់នៅក្បែរនោះ ដើម្បីឱ្យអ្នកតវ៉ា ងាយស្រួលទំនាក់ទំនង ។ រាល់ការតវ៉ា ឬជំទាស់ណាមួយនោះ អាចធ្វើទៅបានតាមរយៈមេភូមិសាមី សមាជិកគណៈកម្មការតំណាងភូមិនិមួយៗ ប្រធានគណៈកម្មការសហគមន៍នេសាទ ឬតាមរយៈលោកមេឃុំឫស្សីកែវផ្ទាល់តែម្តង ដោយត្រូវបញ្ជូនការតវ៉ាឬជំទាស់នោះបន្តមកខណ្ឌរដ្ឋបាលជលផលក្រចេះ ។

បន្ទាប់មកលោក **បែន ប៊ុណ្ណារ៉ាវុធ** នាយផ្នែករដ្ឋបាលជលផលព្រែកប្រសព្វបានឡើងធ្វើបទបង្ហាញដោយសង្ខេបពីចំណុចនិយាមកាទាំងសាបសិបពីរចំណុច ដែលក្រុមការងារបានចុះប្រមូលយកនៅតំបន់គោលដៅបឹងវែង បឹងកាហាត ប្រឡាយអូរជង និងកន្លែងអភិរក្សត្រីមេពូជ ព្រមទាំងបានផ្តល់ឱកាសដល់អ្នកចូលរួមទាំងអស់ លើកជាសំណួរ កង្វល់ និងការជំទាស់តវ៉ាផ្សេងៗ។ កិច្ចប្រជុំក៏បានពិភាក្សា និងឯកភាពគ្នាលើចំណុចទីតាំងនានាដែលត្រូវបិទផ្សាយផែនទី រួមមានសាលាឃុំ វត្តអារាម និងទីប្រជុំជនក្នុងភូមិនិមួយៗ និងបានចាត់ចែងក្រុមការងារចុះបិទផ្សាយផែនទីទៅតាមទីតាំងដែលបានកំណត់ ។

ចុងបញ្ចប់នៃកម្មវិធី លោក **សៀន គិន** នាយខណ្ឌរដ្ឋបាលជលផលក្រចេះ និងជាប្រធានគម្រោងគ្រប់គ្រងធនធានទឹកចម្រុះថ្នាក់ខេត្ត បានស្នើអោយអាជ្ញាធរភូមិ ឃុំ និងគណៈកម្មការធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយបន្ថែមទៀត ក្នុង

រយៈពេលសាបសិបថ្ងៃគិតចាប់ពីថ្ងៃបិទផ្សាយនេះ រហូតដល់ថ្ងៃទីដប់មួយ ខែកក្កដា ឆ្នាំពីរពាន់ដប់ប្រាំបួន ក្នុងគោលដៅធ្វើយ៉ាងណាប្រមែប្រមូលយកមតិយោបល់ និងការជំទាស់តវ៉ាផ្សេងៗ ដើម្បីរកដំណោះស្រាយតាមលទ្ធភាពដែលអាចធ្វើបាន។ លោកនាយខណ្ឌ ក៏បានថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់ ដែលចំណាយពេលវេលាដ៏មានតម្លៃ អញ្ជើញមកចូលរួមក្នុងកម្មវិធីប្រជុំផ្សព្វផ្សាយសេចក្តីព្រាងផែនទី កន្លែងនេសាទសហគមន៍ឫស្សីកែវនាថ្ងៃនេះ និងជូនពរដល់អ្នកចូលរួមទាំងអស់ឱ្យជួបប្រទះតែជ័យជំនះគ្រប់ភារកិច្ច ព្រមទាំងប្រកាសបិទអង្គប្រជុំ ។

កំណត់ហេតុនេះ បានចប់សព្វគ្រប់ នៅម៉ោងដប់មួយ និងសាមសិបប្រាំនាទី នាថ្ងៃទីខែឆ្នាំដដែល ស្ថិតក្រោមបរិយាកាស រីករាយ ស្និទ្ធស្នាល គិចូសហការល្អ និងក្នុងស្មារតីយកចិត្តទុកដាក់ខ្ពស់លើការអភិរក្សធនធានជលផល ។

**អ្នកធ្វើកំណត់ហេតុ**

**បានឃើញនិងឯកភាព**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុ
## ស្តីពី
## ការប្រជុំចុះកំណត់និយាមកានៅបឹងវែង ឬបឹងធំ និងកន្លែងអភិរក្សត្រីមេពូជ

ឯកស័ក ពុទ្ធសករាជពីរពាន់ប្រាំរយហុកសិបពីរ ឆ្នាំកុរ ខែចេត្រ ថ្ងៃពុធ ដប់ពីររោច ត្រូវនឹងឆ្នាំពីរពាន់ដប់ប្រាំបួន ខែឧសភា ថ្ងៃទីមួយ វេលាម៉ោងប្រាំបី និងដប់ប្រាំនាទីព្រឹក នៅចំណុចចុងទួលមាត់បឹងវែង ភូមិឫស្សីកែវ ឃុំឫស្សីកែវ មានកិច្ចប្រជុំមួយ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ នៅទីតាំងចំណុចគោលដៅនៅលើផែនទីគំនូសព្រាងទី១ ដែលត្រូវចុះយកនិយាមកាដល់ទីតាំងជាក់ស្តែង សម្រាប់រៀបចំធ្វើផែនទីកន្លែងនេសាទសហគមន៍ឫស្សីកែវ ដោយមានការចូលរួមពីសមាជិក និងគណៈកម្មការសហគមន៍នេសាទឫស្សីកែវ អាជ្ញាធរភូមិពាក់ព័ន្ធ ឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ រដ្ឋបាលបាលជលផល(នាយកដ្ឋានអភិវឌ្ឍសហគមន៍នេសាទ ខណ្ឌរដ្ឋបាលជលផលក្រចេះ ផ្នែករដ្ឋបាលជលផលព្រែកប្រសព្វ) និងចាស់ព្រឹទ្ធាចារ្យ ដឹកនាំដោយលោក **គ្រាក់ ផល្លី** មន្ត្រីរដ្ឋបាលសាលាស្រុកព្រែកប្រសព្វ ជាតំណាងអភិបាលនៃគណៈអភិបាលស្រុកព្រែកប្រសព្វ និងលោក **សៀន គិន** នាយខណ្ឌរដ្ឋបាលជលផលក្រចេះ និងជាតំណាងរដ្ឋបាលជលផល ដោយមានសមាសភាពអញ្ជើញចូលរួមដូចខាងក្រោម៖

| | |
|---|---|
| ១ - លោក ស៊ូ ហ្សូត្រា | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ |
| ២ - លោក បែន ប៊ុណ្ណារ៉ាវុធ | នាយផ្នែករដ្ឋបាលជលផលព្រែកប្រសព្វ |
| ៣ - លោក ហុក វ៉ាមិហ៍ | សមាជិកក្រុមប្រឹក្សាឃុំឫស្សីកែវ |
| ៤ - លោកស្រី ហុក គយ | ប្រធានសហគមន៍នេសាទឫស្សីកែវ |
| ៥ - លោក ទូច គឹមឆាន | ទីប្រឹក្សាសហគមន៍នេសាទថ្នាក់ជាតិ គម្រោង M-IWRM-P3 |
| ៦ - លោក អ៊ុក ធីរ៉ា | ទីប្រឹក្សាសហគមន៍នេសាទថ្នាក់ខេត្ត គម្រោង M-IWRM-P3 |

៧ - បញ្ជីវត្តមានគណៈកម្មការ និងសមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធអញ្ជើញចូលរួម

ជាកិច្ចចាប់ផ្តើមលោក **សៀន គិន** នាយខណ្ឌរដ្ឋបាលជលផលក្រចេះ និងជាប្រធានគម្រោងថ្នាក់ខេត្ត បានមានមតិស្វាគមន៍បើកអង្គប្រជុំ និងបានលើកយកពីទីតាំងចំណុចដៅទាំងឡាយនៅបឹងវែង ដែលអង្គប្រជុំបានជជែក ពិភាក្សាគ្នានៅក្នុងកិច្ចប្រជុំមួយនៅសាលាឃុំឫស្សីកែវកាលពីព្រឹកថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ មកធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់នៅលើទីតាំងជាក់ស្តែង។

បន្ទាប់មកលោក **ហុក វ៉ាមិហ៍** និងសមាជិកសហគមន៍នេសាទ ដែលមានទីលំនៅក្បែរបឹងវែង បានគូសបញ្ជាក់បន្ថែមនៅលើផែនទីគំនូសព្រាងទី១ ដើម្បីបង្ហាញដល់អ្នកចូលរួមបានយល់ដឹងកាន់តែស៊ីជម្រៅថែមទៀតពីឈ្មោះផ្លូវ ទំនប់ អូរ ប្រឡាយ ឈូង ជ្រោយ វាលស្រែ ចំការ និងទីតាំងច្រកផ្លូវដែលត្រូវចុះទៅយកនិយាមកាជាក់ស្តែង។

បន្ទាប់ពីអ្នកចូលរួមទាំងអស់គ្នា បានស្គាល់ពីទីតាំងតាមចំណុចនីមួយៗច្បាស់លាស់រួចរាល់ហើយ ក្រុមការងារចម្រុះបានធ្វើដំណើរតាមផ្លូវទឹកដោយមធ្យោបាយជួលទូកម៉ាស៊ីនចំនួន០៤គ្រឿងឆ្ពោះទៅកាន់ទីតាំងគោលដៅជាក់ស្តែងតាមចំណុចទាំងនោះតាមលំដាប់លំដោយ ដើម្បីកំណត់យកនិយាមកាជាក់ស្តែង ។

ជាលទ្ធផលការកំណត់យកនិយាមកាជាក់ស្តែង ដោយមានការឯកភាពគ្នាជាឯកច្ឆន្ទ កំណត់ព្រំប្រទល់ ដើម្បីរៀបចំផែនទីកន្លែងនេសាទសហគមន៍ឫស្សីកែវ ដោយកំណត់យកចំណុចនិយាមកានៅបឹងវែង ឬបឹងធំ និងកន្លែងអភិរក្សត្រីមេពូជរបស់សហគមន៍ តាមចំណុចគោលដៅជាបន្តបន្ទាប់មានដូចខាងក្រោម៖

## និយាមកាបឹងវែង

| X | Y | ចំណុចគោលដៅ |
|---|---|---|
| ១- 586316 - | 1358831 | ដើមត្រសេកក្បែរផ្លូវ ខាងលិចផ្លូវចុះទៅចុងទួល កែងដីស្រែឈ្មោះស្រឿននៅភូមិឫស្សីកែវ |
| ២- 586009 - | 1359083 | ដើមរាំងខាងលិចច្រកច្រកែង កែងនឹងចុងដីស្រែឈ្មោះហេង ប្រពន្ធឈ្មោះវន នៅភូមិឫស្សីកែវ |
| ៣- 585931 | 1359442 | ដើមរាំងច្រករោងចាម កែងចុងដីស្រែឈ្មោះ មាន នៅភូមិឫស្សីកែវ |
| ៤- 585605 | 1359638 | ដើមរាំងច្រកថ្មោម ចុងដីស្រែឈ្មោះ តា វ៉ាន់ នៅភូមិឫស្សីកែវ |
| ៥- 584923 | 1359768 | ជ្រោយព្រៃខាងលិច ពយបឹងវែង |
| ៦- 584311 | 1361144 | ដើមត្រសេកធំ ចុងដីស្រែឈ្មោះ វី នៅភូមិស្រទ្បៅដំណាក់ |
| ៧- 586276 | 1362418 | ច្រកភូមិត្មោត ចុងស្ទឹង |
| ៨- 587019 | 1361161 | ដើមពពូលធំ ជ្រោយចង្អឹង ខាងកើតបឹងវែង |
| ៩- 587415 | 1360078 | ផ្ទាំងថ្ម ក្រោមដើមត្រសេកធំ ជ្រោយតាចក់ ខាងកើតបឹងវែង |
| ១0- 587186 | 1358943 | ដើមរាំងធំ២ដើម ចុងដីស្រែឈ្មោះ ណាល់ វ៉ន នៅភូមិស្វាយជុំ ។ |

## និយាមកាកន្លែងអភិរក្សត្រីមេពូជ

| | | |
|---|---|---|
| ១ - 586731 | 1359785 | បង្គោលកែងខាងជើង ឈៀងខាងកើតកន្លែងអភិរក្ស |
| ២ - 586646 | 1359407 | បង្គោលកែងខាងកើត ឈៀងខាងត្បូងកន្លែងអភិរក្ស |
| ៣ - 586383 | 1359395 | បង្គោលកែងខាងត្បូងឈៀងខាងលិចកន្លែងអភិរក្ស |
| ៤ - 586441 | 1359801 | បង្គោលកែងខាងលិចឈៀងខាងជើងកន្លែងអភិរក្ស។ |

បន្ទាប់ពីបានចុះកំណត់យកនិយាមកាតាមចំណុចដៅនីមួយៗសម្រេចតាមផែនការ ដែលបានគ្រោងទុករួចរាល់នោះ លោក **សៀន គិន** នាយខណ្ឌរដ្ឋបាលជលផលក្រចេះ និងជាប្រធានគម្រោងថ្នាក់ខេត្ត បានថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងការចុះយកនិយាមកាជាក់ស្តែងនៅបឹងវែង ឬបឹងធំ និងកន្លែងអភិរក្សត្រីមេពូជរបស់សហគមន៍នេសាទឫស្សីកែវ ដើម្បីរៀបចំធ្វើផែនទីកន្លែងនេសាទសហគមន៍ឫស្សីកែវនៅថ្ងៃនេះ។ ជាចុងក្រោយ លោកនាយខណ្ឌ បានជូនពរដល់អ្នកចូលរួមទាំងអស់ សូមឱ្យជួបប្រទះតែជ័យជំនះគ្រប់ភារកិច្ច ព្រមទាំងប្រកាសរំសាយ។

កំណត់ហេតុនេះ បានបញ្ចប់ចប់សព្វគ្រប់នៅម៉ោងដប់ប្រាំពីរ និងម្ភៃបីនាទី នាថ្ងៃទីខែឆ្នាំដដែល ស្ថិតក្រោមបរិយាកាស រីករាយ ស្និទ្ធស្នាល កិច្ចសហការល្អ និងក្នុងស្មារតីទទួលខុសត្រូវផ្តោតលើការគ្រប់គ្រងធនធានជលផល ។

**អ្នកធ្វើកំណត់ហេតុ**

**បានឃើញនិងឯកភាព**
**ប្រធានអង្គប្រជុំ**

**សៀន គិន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### កំណត់ហេតុ
### ស្តីពី
### ការប្រជុំចុះកំណត់និយាមកានៅបឹងកាហាត និងអូរជង

ឯកស័ក ពុទ្ធសករាជពីរពាន់ប្រាំរយហុកសិបពីរ ឆ្នាំកុរ ខែចេត្រ ថ្ងៃអង្គារ ដប់មួយរោច ត្រូវនឹងឆ្នាំពីរពាន់ដប់ប្រាំបួន ខែមេសា ថ្ងៃទីសាមសិប វេលាម៉ោងដប់បួន និងដប់ប្រាំនាទី នៅលើទំនប់អូរជង ភូមិបឹងរៃ ឃុំឫស្សីកែវ មានកិច្ចប្រជុំមួយ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ឡើងវិញ នៅទីតាំងចំណុចគោលដៅនៅលើផែនទីគំនូសព្រាងទី១ ដែលត្រូវចុះយកនិយាមកា ដល់ទីតាំងជាក់ស្តែង សម្រាប់រៀបចំធ្វើផែនទីកន្លែងនេសាទសហគមន៍ឫស្សីកែវ ដោយមានការចូលរួមពីសមាជិក និងគណៈកម្មការសហគមន៍នេសាទឫស្សីកែវ អាជ្ញាធរភូមិពាក់ព័ន្ធ ឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ រដ្ឋបាលបាលជលផល (នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ ខណ្ឌរដ្ឋបាលជលផលក្រចេះ ផ្នែករដ្ឋបាលជលផលព្រែកប្រសព្វ) និងចាស់ព្រឹទ្ធាចារ្យ ដឹកនាំដោយ លោក **ត្រាំ ផល្លី** មន្ត្រីរដ្ឋបាលសាលាស្រុកព្រែកប្រសព្វ ជាតំណាងអភិបាលនៃគណៈអភិបាលស្រុកព្រែកប្រសព្វ និង លោក **សៀន គិន** នាយខណ្ឌរដ្ឋបាលជលផលក្រចេះ និងជាតំណាងរដ្ឋបាលជលផល ដោយមានសមាសភាពអញ្ជើញចូលរួមដូចខាងក្រោម៖

| | |
|---|---|
| ១- លោក ស៊ូ ហប្បត្រា | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ |
| ២- លោក បែន ប៊ុណ្ណារ៉ាវុធ | នាយផ្នែករដ្ឋបាលជលផលព្រែកប្រសព្វ |
| ៣- លោក នី សោម | ជំទប់ទី១ឃុំឫស្សីកែវ |
| ៤- លោកអ៊ួង ប៊ុនរិទ្ធ | អនុភូមិស្រឡៅដំណាក់ |
| ៥- លោកស្រី ហុក កយ | ប្រធានសហគមន៍នេសាទឫស្សីកែវ |
| ៦- លោក ទូច គឹមឆាន | ទីប្រឹក្សាសហគមន៍នេសាទថ្នាក់ជាតិ គម្រោង M-IWRM-P3 |
| ៧- លោក អ៊ុក ធីរ៉ា | ទីប្រឹក្សាសហគមន៍នេសាទថ្នាក់ខេត្ត គម្រោង M-IWRM-P3 |

៨- បញ្ជីវត្តមានគណៈកម្មការ និងសមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធអញ្ជើញចូលរួម

ជាកិច្ចចាប់ផ្តើមលោក **សៀន គិន** នាយខណ្ឌរដ្ឋបាលជលផលក្រចេះ និងជាប្រធានគម្រោងថ្នាក់ខេត្ត បានមានមតិស្វាគមន៍បើកអង្គប្រជុំ និងបានលើកយកពីទីតាំងចំណុចដៅទាំងឡាយនៅបឹងកាហាត និងអូរជង ដែលអង្គប្រជុំបានជជែកពិភាក្សាគ្នានៅក្នុងកិច្ចប្រជុំមួយ នៅសាលាឃុំឫស្សីកែវកាលពីព្រឹកមិញ មកធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ នៅលើទីតាំងជាក់ស្តែង។

បន្ទាប់មក លោកនី **សោម** ជំទប់ទី១ឃុំ លោក **អ៊ួង ប៊ុនរិទ្ធ** អនុភូមិស្រឡៅដំណាក់ និងសមាជិកសហគមន៍នេសាទដែលមានទីលំនៅក្បែរបឹងកាហាត និងអូរជង បានគូសបញ្ជាក់បន្ថែមនៅលើផែនទីគំនូសព្រាងទី១ ដើម្បីបង្ហាញដល់អ្នកចូលរួមបានយល់ដឹងកាន់តែស៊ីជម្រៅថែមទៀត ពីឈ្មោះផ្លូវ ទំនប់ អូរប្រឡាយ ឈូង ជ្រោយ វាលស្រែ ចំការ និងទីតាំងច្រកផ្លូវដែលត្រូវចុះទៅយកនិយាមកាជាក់ស្តែង ។

បន្ទាប់ពីអ្នកចូលរួមទាំងអស់គ្នា បានស្គាល់ទីតាំងតាមចំណុចនីមួយៗច្បាស់លាស់រួចរាល់ហើយ ក្រុមការងារចម្រុះរៀបចំធ្វើផែនទី ក៏បានធ្វើដំណើរដោយមធ្យោបាយរថយន្តគម្រោងចំនួន០២គ្រឿង និងជួលម៉ូតូចំនួន០៩គ្រឿងឆ្ពោះទៅកាន់ទីតាំងចំណុចទាំងនោះតាមលំដាប់លំដោយ ដើម្បីកំណត់និយាមកាជាក់ស្តែង ។

ជាលទ្ធផលការកំណត់យកនិយាមកាជាក់ស្តែង ដោយមានការឯកភាពគ្នាជាឯកច្ឆន្ទ កំណត់ព្រំប្រទល់ ដើម្បីរៀបចំផែនទី

កន្លែងនេសាទសហគមន៍ឫស្សីកែវ ដោយកំណត់យកចំណុចនិយាមកានៅបឹងកាហាត និងអូរជង តាមចំណុចគោលដៅជាបន្តបន្ទាប់មានដូចខាងក្រោម៖

**និយាមកាបឹងកាហាត:**

| X | Y | ចំណុចគោលដៅ |
|---|---|---|
| ១ - 584525 | 1359925 | ដើមត្រស់កំពង់ទូកតាជីន |
| ២ - 583675 | 1359585 | ដើមរាំងកំពង់ទូកតាប្រុក |
| ៣ - 582666 | 1359065 | ដើមរាំងមាត់ប្រឡាយស្ថានីយ៍បូមទឹកក្រោយវត្តបឹងរៃ |
| ៤ - 582172 | 1359385 | ដើមរាំងខាងលិចឈៀងខាងត្បូងបឹងកាហាត ចុងដីស្រែឈ្មោះ តា ទុយ នៅភូមិបឹងរៃ |
| ៥ - 582388 | 1359853 | ដើមជាលាខាងលិច ឈៀងខាងជើងបឹងកាហាត( លោកប៉ុក ហ៊ុន លី ចុះទៅយកចំណុចក្នុងព្រៃលិចទឹកជ្រៅ ឆ្ងាយផុតពីក្បាលដីចំការរបស់ប្រជាពលរដ្ឋ) |
| ៦ - 582748 | 1360489 | ដើមជាលាខាងជើងឈៀងខាងលិចបឹងកាហាតចុងដីស្រែឈ្មោះ តា ជូ នៅភូមិបឹងរៃ |
| ៧ - 583225 | 1360541 | ចម្ងាយប្រមាណ៥ម ខាងត្បូងដើមជាលាមាត់ប្រឡាយទំនប់បឹងកាហាត ចុងដីស្រែឈ្មោះ ពិសិដ្ឋ នៅភូមិស្រឡៅដំណាក់ |
| ៨ - 583565 | 1360588 | ដើមរាំងក្បែរផ្លូវទៅកំពង់ចុះទូកបឹងកាហាត ចុងដីស្រែឈ្មោះ ម៉ាប់ នៅភូមិស្រឡៅដំណាក |

**និយាមកាប្រឡាយអូរជង:**

| X | Y | ចំណុចគោលដៅ |
|---|---|---|
| ៩ - 584032 | 1361151 | ខាងកើតមាត់ប្រឡាយអូរជងចំណុចព្រំប្រទល់ខេត្តក្រចេះ កំពង់ចាម |
| ១០ - 584501 | 1360431 | ខាងជើងមាត់ប្រឡាយអូរជង ខាងលិចកោងប្រឡាយអូរជង |
| ១១ - 584757 | 1359808 | ទល់មុខឬទន្ទឹមនឹងបង្គោលទី២៦ ខាងកើតប្រឡាយអូរជង |
| ១២ - 584309 | 1359379 | ទល់មុខឬទន្ទឹមនឹងបង្គោលទី២៥ ខាងត្បូងប្រឡាយអូរជង |
| ១៣ - 583482 | 1358818 | ដើមរាំងខាងកើត ក្បាលប្រឡាយអូរជងខាងលិចជួរដើមត្នោតភូមិស្រឡៅដំណាក់ |
| ១៤ - 583433 | 1358818 | ចម្ងាយ៥៣មខាងលិចបង្គោលទី១ខាងលិចជួរដើមត្នោតនៅភូមិស្រឡៅដំណាក់ |
| ១៥ - 584291 | 1359419 | ដើមរាំងខាងជើងប្រឡាយអូរជង ចុងដីស្រែឈ្មោះ តា ឈុំ នៅភូមិស្រឡៅដំណាក់ |
| ១៦ - 584694 | 1359808 | ដើមសណ្តាន់ខាងលិចប្រឡាយអូរជងមុខដីស្រែឈ្មោះគៀត ស៊ីយាងនៅភូមិបឹងរៃ |
| ១៧ - 584475 | 1360375 | ខាងត្បូងមាត់ប្រឡាយអូរជង ខាងលិចកោងអូរជង |
| ១៨ - 583988 | 1361118 | ខាងលិចមាត់ប្រឡាយអូរជង ចំណុចព្រំប្រទល់ខេត្តក្រចេះ កំពង់ចាម |

បន្ទាប់ពីបានចុះកំណត់និយាមកាតាមចំណុចដៅនីមួយៗ សម្រេចតាមផែនការ ដែលបានគ្រោងទុករួចហើយ លោក សៀន គិន នាយខណ្ឌរដ្ឋបាលជលផលក្រចេះ និងជាប្រធានគម្រោងថ្នាក់ខេត្ត បានថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងការចុះប្រមូលទិន្នន័យនិយាមកា នៅបឹងកាហាត និងអូរជង ដើម្បីរៀបចំធ្វើផែនទីកន្លែងនេសាទសហគមន៍ឫស្សីកែវនៅថ្ងៃនេះ ។ ជាចុងក្រោយ លោកនាយខណ្ឌបានជូនពរដល់អ្នកចូលរួមទាំងអស់ សូមឱ្យជួបប្រទះនូវពុទ្ធពរបួនប្រការ ព្រមទាំងប្រកាសបិទអង្គប្រជុំ។

កំណត់ហេតុនេះ បានបញ្ចប់នៅម៉ោងដប់ប្រាំពីរ និងសែសិបនាទី នាថ្ងៃទីខែឆ្នាំដដែល ស្ថិតក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល កិច្ចសហការល្អ និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់លើការអភិរក្សធនធានជលផល ។

**អ្នកធ្វើកំណត់ហេតុ**

**បានឃើញនិងឯកភាព**
**ប្រធានអង្គប្រជុំ**

**សៀន គិន**